# ទីស្តីការគណៈរដ្ឋមន្ត្រី

# ការណែនាំស្តីពី
# ការវិភាគបន្ទុកចំណាយ និងផលចំណេញ

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត

ដាក់ឲ្យប្រើប្រាស់នៅខែឧសភា ២០១៧

# មាតិកា

បុព្វកថា..........................................................................២

សេចក្តីផ្តើម ......................................................................៥

ការវិភាគបន្ទុកចំណាយ និងផលចំណេញនៅក្នុងការវិភាគ
លើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត.......................១០

តើការវិភាគបន្ទុកចំណាយ និងផលចំណេញគឺជាអ្វី? .......១២

ដំណាក់កាលនៅក្នុងការវិភាគបន្ទុកចំណាយ
និងផលចំណេញ.........................................................១៤

ការដោះស្រាយជាមួយបន្ទុកចំណាយ និងផលចំណេញ ដែល
លំបាកកំណត់ជាតម្លៃចំពោះការគណនា...........................៣២

ការពិចារណាផ្នែកសមធម៌............................................៤៤

កំហុសធម្មតានៃការវិភាគបន្ទុកចំណាយ និងផលចំណេញ...៤៧

ឯកសារយោងនិងព័ត៌មានបន្ថែម....................................៥២

ឧបសម្ព័ន្ធ- ឧទាហរណ៍នៃការវិភាគបន្ទុកចំណាយ
និងផលចំណេញ........................................................៥៣

# បុព្វកថា

រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តែងតែចាត់ទុកវិស័យឯកជនជាម៉ាស៊ីនសម្រាប់កំណើនសេដ្ឋកិច្ចដែលត្រូវបានចង្អុលបង្ហាញយ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រចតុកោណ និងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានបង្កើតនិងបន្តធ្វើគោលនយោបាយ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន។

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) ត្រូវបានគេទទួលស្គាល់ថាជាឧបករណ៍មានប្រសិទ្ធភាពក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តកាន់តែប្រសើរ។ ទោះជាយ៉ាងណាក៏ដោយ ការលំបាកបំផុតក្នុងដំណើរការ RIA គឺការវិភាគបន្ទុកចំណាយនិងផលចំណេញ (Cost and Benefit Analysis - CBA)។ វាមិនងាយស្រួលក្នុងការកំណត់ជាបរិមាណឬជាទឹកប្រាក់នោះទេ។ សៀវភៅមគ្គុទ្ទេសក៍នេះនឹងបង្ហាញនូវវិធីសាស្ត្រដ៏ទូលំទូលាយមួយរបស់ CBA ដែលពិតជានឹងជួយសម្របសម្រួលដល់មន្ត្រីក្រសួង ស្ថាប័ននៅក្នុងការរៀបចំរបាយការណ៍RIAឲ្យបានគ្រប់ជ្រុងជ្រោយលើលិខិតបទដ្ឋានគតិយុត្តដែលបានស្នើឡើង។

ខ្ញុំសូមឆ្លៀតឱកាសនេះដើម្បីថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានគាំទ្រយ៉ាងពេញទំហឹងចំពោះការអនុវត្ត RIA នៅកម្ពុជា និងចេញសេចក្តីសម្រេចលេខ១៣២ ស.សរ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៦ ស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅក្នុងគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការងារRIAក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត នៅក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលទទួលខុសត្រូវក្នុងការងារបណ្តុះបណ្តាលនិងការណែនាំអនុវត្តRIA ការធ្វើបច្ចុប្បន្នភាពនិងការបោះពុម្ពផ្សាយវិធីសាស្ត្រRIA។

ខ្ញុំសូមសម្តែងការដឹងគុណចំពោះសម្តេចវិបុលបញ្ញា ដែលជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី(បានទទួលមរណៈភាព) ដែលបានគាំទ្រយ៉ាងរឹងមាំ និងផ្តល់ការណែនាំចាំបាច់ក្នុងការបង្កើតកម្មវិធីRIA។

ខ្ញុំសូមវាយតម្លៃខ្ពស់ និងកោតសរសើរដល់ការខិតខំប្រឹងប្រែងរបស់ក្រុមការងារRIAនៅECOSOCC ដឹកនាំដោយឯកឧត្តម **យឹម ណុលសន** អនុប្រធានECOSOCC និងគ្រប់គ្រង

ដោយឯកឧត្តម **ប៉ិច សុខា** អគ្គលេខាធិការរងECOSOCC ដែលបានរៀបចំបោះពុម្ពផ្សាយសៀវភៅមគ្គុទ្ទេសក៍CBAនេះឡើង និងជំនួយដ៏មានតម្លៃរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដល់ ECOSOCCក្នុងការអនុវត្តកម្មវិធីRIA។ ខ្ញុំក៏សូមថ្លែងអំណរអរគុណដ៏ស្មោះផងដែរ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក Chris Toyne ទីប្រឹក្សាជាន់ខ្ពស់នៅការិយាល័យប្រតិបត្តិល្អលិខិតបទដ្ឋានគតិយុត្តនៃនាយកដ្ឋាននាយករដ្ឋមន្ត្រី និងខុទ្ទកាល័យនៃរដ្ឋាភិបាលអូស្ត្រាលី ក្នុងការចូលរួមចំណែករបស់គាត់ក្នុងការបោះពុម្ពសៀវភៅណែនាំនេះនិងវគ្គបណ្តុះ-បណ្តាល CBA ជូនសមាជិកនៃក្រុមការងារRIA នៅថ្ងៃទី១៣ ដល់ ទី១៦ ខែកញ្ញា ឆ្នាំ ២០១៦។

**ឯកឧត្តម យឹម ណុលឡា**

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

និងជាប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌

# សេចក្តីផ្តើម

## ផែនទីចង្អុលបង្ហាញអំពីកម្មវិធីវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តនៅកម្ពុជា

កម្មវិធីRIAនៅកម្ពុជាសំដៅពង្រឹងភាពប្រកួតប្រជែងនិងប្រសិទ្ធភាពនៃបញ្ញត្តិកម្ម តាមរយៈការដាក់ឱ្យអនុវត្តនូវគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តនៅតាមក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល។ ប្រព័ន្ធRIA តម្រូវឱ្យក្រសួងនីមួយៗអនុវត្តតាមគោលការណ៍ប្រតិបត្តិល្អ និងវាយតម្លៃលើស្មារតីឬខ្លឹមសារនៃបទប្បញ្ញត្តិដែលមានផលប៉ះពាល់ដល់បន្ទុកចំណាយនិងការប្រកួតប្រជែងរបស់ធុរកិច្ច។

កម្មវិធីនេះបានចាប់ផ្តើមក្នុងឆ្នាំ ២០១១ ជាគម្រោងសាកល្បង ក្រោមហិរញ្ញប្បទានឥតសំណងពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមការងារប្រតិបត្តិគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(ORIA) ដែលត្រូវបានបង្កើតឡើងនៅក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីផ្តល់ការណែនាំ និងការបណ្តុះបណ្តាលអំពីវិធីសាស្ត្រRIA ដល់ក្រសួង ស្ថាប័នដោយឈរលើគោលការណ៍ប្រតិបត្តិល្អក្នុងនីតិវិធីរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត

និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នក្នុងការអនុវត្តRIAផង ហើយទទួលគ្រប់គ្រងដំណើរការនៃកម្មវិធីទាំងមូល។

នៅដំណាក់កាលដំបូងនៃគម្រោងសាកល្បងនេះ មានក្រសួង ស្ថាប័នចំនួន ៤ (ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន អតីតក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល និងក្រសួងទេសចរណ៍) បានចូលរួមក្នុងកម្មវិធីសាកល្បងអនុវត្តវិធីសាស្ត្រRIAក្នុងដំណើរការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត។ ក្រសួង ស្ថាប័ននីមួយៗខាងលើ មានមន្ត្រីចំនួន៨រូប និង មន្ត្រីRIA នៃECOSOCC មានមន្ត្រីចំនួន១៣រូប ហើយមន្ត្រីRIA បានទទួលជំនួយនិងការបណ្តុះបណ្តាលអំពីRIA ពីក្រុមទីប្រឹក្សាជាតិនិងអន្តរជាតិផ្តល់ដោយADB សម្រាប់ការអភិវឌ្ឍកម្មវិធីនិងបណ្តុះបណ្តាលរហូតដល់ខែមីនា ឆ្នាំ២០១៣។ តាំងពីពេលនោះមក ORIA នៃ ECOSOCC បានទទួលបន្ទុកពេញលេញក្នុងការអភិវឌ្ឍកម្មវិធីរួមបញ្ចូលទាំងការបណ្តុះបណ្តាលនិងការបង្ហាត់បង្រៀនដោយខ្លួនឯង។

ដោយសារឃើញភាពជោគជ័យក្នុងការអនុវត្តគម្រោងតាមការវាយតម្លៃរបស់បេសកកម្មត្រួតពិនិត្យរបស់ADB សម្រាប់ពាក់កណ្តាលអាណត្តិនៃគម្រោង ដែលបានធ្វើឡើងនៅខែមិថុនា ឆ្នាំ២០១៣ ទីស្តីការគណៈរដ្ឋមន្ត្រី និងADBបានឯកភាពឲ្យECOSOCC បញ្ចូលក្រសួង៣ទៀត គឺក្រសួងកសិកម្ម

រុក្ខាប្រមាញ់និងនេសាទ ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងកម្មវិធីRIA នៅខែមករា ឆ្នាំ២០១៤។ ជំនួយឥតសំណងនេះ ត្រូវបានពន្យាររហូតដល់ពេលមានជំនួយបច្ចេកទេស(TA)ថ្មីបានចាប់ផ្តើមនៅដើមឆ្នាំ ២០១៦។

នៅអំឡុងពេលអនុវត្តគម្រោង ការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងអំពីRIAជាច្រើនត្រូវបានរៀបចំឡើងដោយ ECOSOCC និងADB នៅតាមក្រសួង ស្ថាប័ន អគ្គលេខាធិការដ្ឋានរដ្ឋសភាដែលមានមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមផងដែរ សាកលវិទ្យាល័យនានា និងវិស័យឯកជន ដែលមានអ្នកចូលរួមសរុបប្រមាណជាង ៩៥០០នាក់ ហើយដែលទាំងអស់គ្នាក៏បានគាំទ្រយ៉ាងខ្លាំងដល់វិធីសាស្ត្រRIA និងចង់បានឲ្យRIAនេះអនុវត្តនៅប្រទេសកម្ពុជា។

សម្រាប់ឆ្នាំ ២០១៦-២០១៧ ដោយមានការគាំទ្រជាជំនួយបច្ចេកទេសពីADB ECOSOCCបន្តដំណើរការកម្មវិធីRIA ដោយបន្ថែមក្រសួងថ្មីចំនួន ៦ នៅឆ្នាំ២០១៦ រួមមាន ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងរៀបចំដែនដី នគររូបនីយកម្មនិងសំណង់ និងក្រសួងថ្មីចំនួន ៦ ទៀត នឹងត្រូវបញ្ចូលក្នុងឆ្នាំ២០១៧។

ដោយឃើញអត្ថប្រយោជន៍នៃដំណើរការRIA រដ្ឋាភិបាលកម្ពុជាបានចេញសេចក្តីសម្រេច (សេចក្តីសម្រេចរបស់រដ្ឋាភិបាលលេខ ១៣២) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ដើម្បីឲ្យក្រសួង ស្ថាប័នទាំងអស់បង្កើតក្រុមការងារRIAមួយ សម្រាប់ការរៀបចំសំណើលិខិតបទដ្ឋានគតិយុត្តរបស់ពួកគេ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលពេញលេញពីECOSOCC ។

យោងតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ១៣២ ECOSOCCបានបង្កើតក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តជាផ្លូវការនៅថ្ងៃទី៧ ខែមករា ឆ្នាំ២០១៧ ជំនួសការិយាល័យRIA ដើម្បីបន្តកម្មវិធីRIA។

សម្រាប់ព័ត៌មានលម្អិតអំពីកម្មវិធីRIAក្នុងប្រទេសកម្ពុជា អ្នកអាចចូលមើលក្នុងគេហទំព័រ(www.ecosocc.gov.kh)។ ប្រសិនបើអ្នកចង់យល់ដឹងទិដ្ឋភាពរួមអំពីRIA អ្នកអាចទាក់ទងជាមួយមន្ត្រីORIA ដើម្បីឲ្យមន្ត្រីORIAធ្វើបទបង្ហាញជូន។

## អំពីមគ្គុទេសក៍

មគ្គុទេសក៍នេះនឹងផ្តល់ការណែនាំអំពីការវិភាគបន្ទុកចំណាយនិងផលចំណេញ ដែលហៅកាត់ថា CBA ប្រើប្រាស់សម្រាប់វិភាគលើសំណើបញ្ញត្តិកម្ម ដោយយោងតាមមគ្គុទេសក៍ CBAទូលំទូលាយនេះ ដូចជាកូនសៀវភៅស្តីពីការវិភាគបន្ទុកចំណាយនិងផលចំណេញរបស់រដ្ឋាភិបាលអូស្ត្រាលី

(Commonwealth of Australia 2006) ឬ សៀវភៅ Boardman et. al. (2010) សម្រាប់ការណែនាំលម្អិត។

មគ្គុទេសក៍CBA ភាគច្រើនផ្តោតទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលមានការងាយស្រួលក្នុងការវាស់វែង។ មគ្គុទេសក៍ CBA នៅទីនេះអនុវត្តទៅលើសំណើបញ្ញត្តិកម្មដែលមានផលប៉ះពាល់មិនច្បាស់លាស់ និងពិបាកកំណត់ជាបរិមាណ។

ប្រធានបទនៅក្នុងមគ្គុទេសក៍នេះរួមមាន ការណែនាំពីដំណាក់កាលក្នុងការរៀបចំCBA វិធីដោះស្រាយនៅពេលCBA លំបាកក្នុងវាស់វែង គិតពិចារណាពីឥទ្ធិពលសមធម៌ កំណត់អត្រាថយចុះនៃតម្លៃសង្គម និងកំហុសធម្មតាខ្លះរបស់CBA។

សម្រាប់ព័ត៌មានបន្ថែម និងជំនួយលើការរៀបចំCBA សូមទាក់ទងការិយាល័យវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត/ក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្តនៃ ECOSOCC (www.ecosocc.gov.kh) ឬអំពីឯកសារយោងមួយចំនួនដែលមាននៅផ្នែកចុងក្រោយនៃមគ្គុទេសក៍នេះ។

## ការវិភាគបន្ទុកចំណាយ និងផលចំណេញ នៅក្នុងការវិភាគផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត

ចំពោះការវិភាគផលប៉ះពាល់នៃលិខិតទបដ្ឋានគតិយុត្ត CBA គឺជាវិធីសាស្ត្រនៃការវាយតម្លៃដែលមានបំណងប៉ាន់ស្មាន និងប្រៀបធៀបបន្ទុកចំណាយនិងផលចំណេញសរុបរបស់សំណើគោលនយោបាយជាក់លាក់មួយ។ ជាគោលការណ៍ CBA វាស់វែងប្រសិទ្ធផល ឬឥទ្ធិពលនៃការបែងចែកធនធានពីការកែសម្រួលបញ្ញត្តិកម្ម។ CBA គណនាចេញតម្លៃជាដុល្លារនៃផលចំណេញ និងការបាត់បង់របស់អ្នករងផលប៉ះពាល់ទាំងអស់។ ប្រសិនបើចំនួនសរុបជាវិជ្ជមាន មានន័យថា ផលចំណេញលើសបន្ទុកចំណាយ នោះសំណើបញ្ញត្តិកម្មនឹងបង្កើនប្រសិទ្ធផល។

CBA មានប្រយោជន៍ពីព្រោះ ៖

- ផ្តល់ព័ត៌មានបែបគុណភាពនិងបែបបរិមាណអំពីឥទ្ធិពលដែលអាចកើតមានឡើង របស់លិខិតបទដ្ឋានគតិយុត្តមួយដល់អ្នកធ្វើសេចក្តីសម្រេច
- លើកទឹកចិត្តឱ្យអ្នកធ្វើសេចក្តីសម្រេចគិតពិចារណាពីឥទ្ធិពលវិជ្ជមាន និងអវិជ្ជមានទាំងអស់របស់សំណើបញ្ញត្តិកម្ម ហើយផ្ទុយទៅវិញមិនលើកទឹកចិត្តអ្នកធ្វើ

សេចក្ដីសម្រេច មិនឱ្យសម្រេចដោយផ្អែកតែលើព័ត៌មានអំពីផលប៉ះពាល់ដល់មួយក្រុម នៅក្នុងសហគមន៍នោះឡើយ

- វាយតម្លៃអំពីផលប៉ះពាល់របស់សំណើបញ្ញត្តិកម្មតាមស្តង់ដា ដែលជួយធ្វើឱ្យការសម្រេចមានសង្គតិភាព
- រៀបរាប់អំពីឥទ្ធិពលទំនាក់ទំនងរវាងសំណើបញ្ញត្តិកម្ម និងវិស័យផ្សេងៗទៀតនៃសេដ្ឋកិច្ច (ឧទាហរណ៍ បង្កើនសុវត្ថិភាពអាចកាត់បន្ថយបន្ទុកចំណាយលើការថែទាំសុខភាព) ជួយឱ្យអ្នកធ្វើសេចក្ដីសម្រេចដោយធ្វើឲ្យមានផលចំណេញសុទ្ធច្រើនបំផុតដល់សង្គម
- ជួយកំណត់រកដំណោះស្រាយដែលមានប្រសិទ្ធភាពចំណាយក្នុងការដោះស្រាយបញ្ហា តាមរយៈការកំណត់ និងការវាស់វែងបន្ទុកចំណាយទាំងអស់។

សូម្បីតែនៅពេលមានការលំបាកក្នុងការប៉ាន់ស្មានបន្ទុកចំណាយ និងផលចំណេញខ្លះ CBAធ្វើឲ្យច្បាស់នូវអ្វីដែលជាការសន្មតនិងការវិនិច្ឆ័យ។ ដោយមានបំណងកំណត់ជាបរិមាណនូវបន្ទុកចំណាយ និងផលចំណេញ ហើយក៏លើកទឹកចិត្តឲ្យអ្នកវិភាគពិនិត្យពីផលប៉ះពាល់កាន់តែច្បាស់។

## តើការវិភាគបន្ទុកចំណាយ និងផលចំណេញគឺជាអ្វី?

លិខិតបទដ្ឋានគតិយុត្តដាក់បន្ទុកចំណាយដល់រដ្ឋាភិបាល ធុរកិច្ច និងបុគ្គល។ លិខិតបទដ្ឋានគតិយុត្តមានប្រសិទ្ធភាពនឹងផ្តល់ផលចំណេញនៅពេលគោលបំណងរបស់រដ្ឋាភិបាលត្រូវបានធ្វើឲ្យសម្រេច។

ការវិភាគផលប៉ះពាល់ផ្តល់ឱ្យអ្នកធ្វើសេចក្តីសម្រេចនូវព័ត៌មាន ដើម្បីថ្លឹងថ្លែងរវាងផលប៉ះពាល់វិជ្ជមាន និងផលប៉ះពាល់អវិជ្ជមាន។ ប្រសិនបើអ្នកធ្វើសេចក្តីសម្រេចជ្រើសរើសធ្វើបញ្ញត្តិកម្មដោយគ្មានធ្វើការវិភាគផលប៉ះពាល់ នោះពួកគេប្រហែលជា មិនអាចសម្រេចបាននូវគោលបំណងដែលបានកំណត់ ឬមិនអើពើពីជម្រើសដែលដាក់បន្ទុកចំណាយតិច។ តួនាទីនៃការវិភាគផលប៉ះពាល់ គឺជួយបញ្ចៀសអ្នកធ្វើសេចក្តីសម្រេចខុស។

ដោយប្រើប្រាស់ឧបករណ៍ ដូចជាការវិភាគបន្ទុកចំណាយ និងផលចំណេញ អនុញ្ញាតឱ្យRIAបង្ហាញជម្រើសដែលអាចសម្រេចបាននូវផលចំណេញច្រើនជាងបន្ទុកចំណាយ ដែលបញ្ជាក់ពីផលចំណេញច្បាស់លាស់ និងបង្ហាញពីជម្រើសដែលសម្រេចបាននូវផលចំណេញ ហើយមានបន្ទុកចំណាយតិចជាងគេ។

ការវិភាគច្បាស់លាស់បែបនេះកម្រនឹងធ្វើបានក្នុងស្ថានភាពប្រព័ន្ធRIAកម្រិតលំដាប់ខ្ពស់ និងស្មុគស្មាញភាគច្រើន។ ការតម្រូវឲ្យមានស្តង់ដា(បមាណីយ)ខ្ពស់សម្រាប់ប្រទេសកម្ពុជា អាចនាំឲ្យលទ្ធផលអវិជ្ជមានទៅវិញទេ ដោយវានឹងធ្វើឲ្យការរៀបចំរបាយការណ៍វាយតម្លៃបឋម (PAS) ឬ របាយការណ៍វាយតម្លៃពេញលេញ (RIS) ជួបការលំបាក ហើយនឹងមាន PAS និង RIS តិចតួចត្រូវបានបញ្ចប់។ ទោះបីជា ចំណេះដឹងអំពីឧបករណ៍ CBA អាចជួយណែនាំនូវប្រភេទសំណួរមួយចំនួន ដែលRIA ត្រូវការក៏មិនអាចអនុវត្តឧបករណ៍CBA នេះបានពេញលេញដែរ។

## ដំណាក់កាលនៅក្នុងការវិភាគបន្ទុកចំណាយ និង ផលចំណេញ

ការអនុវត្តCBA តម្រូវឱ្យអ្នកគោរពតាមលំដាប់លំដោយទាំង៩ដំណាក់កាល(តារាងទី១)។

**តារាង១: ដំណាក់កាលក្នុងការរៀបចំការវិភាគបន្ទុកចំណាយ និងផលចំណេញពេញលេញ**

១. កំណត់សំណុំនៃជម្រើសផ្សេងៗ

២. សម្រេចថាតើត្រូវគិតបន្ទុកចំណាយ និងផលចំណេញរបស់នរណា

៣. កំណត់ផលប៉ះពាល់ និងជ្រើសរើសខ្នាតសូចនាករ

៤. ព្យាករណ៍ផលប៉ះពាល់របស់សំណើបញ្ញត្តិកម្មរហូតអស់សុពលភាព

៥. គិតជាទឹកប្រាក់ចំពោះផលប៉ះពាល់(ភ្ជាប់ជាតម្លៃដុល្លារ)

៦. បញ្ចុះតម្លៃចំពោះបន្ទុកចំណាយ និងផលចំណេញអនាគតដើម្បីទទួលបានតម្លៃបច្ចុប្បន្ន

៧. គណនាតម្លៃបច្ចុប្បន្នសុទ្ធរបស់ជម្រើសនីមួយៗ

៨. ធ្វើការវិភាគភាពអាចប្រែប្រួល

៩. ធ្វើសេចក្តីសន្និដ្ឋាន

*Source: Adapted from Boardman et al. (2010).*

## ដំណាក់កាលទី១៖ កំណត់សំណុំនៃជម្រើសផ្សេងៗ

កំណត់ជម្រើសគោលនយោបាយផ្សេងៗដែលអាចធ្វើបាន និងច្បាស់លាស់ ដែលត្រូវយកមកវិភាគ។ ជម្រើស "មិនធ្វើអ្វីទាំងអស់" ឬ ជម្រើស "រក្សាស្ថានភាពធម្មតា" នឹងផ្តល់នូវមូលដ្ឋានប្រៀបធៀបស្ថានភាពដើម ទៅនឹងបន្ទុកចំណាយ និងផលចំណេញរបស់ជម្រើសនីមួយៗដែលបានកំណត់។ ក្នុងករណីខ្លះ ជម្រើស"មិនធ្វើអ្វីទាំងអស់" អាចជាជម្រើសដែលល្អបំផុត។ មានតែបន្ទុកចំណាយនិងផលចំណេញដែលមិនបានកើតឡើងក្នុងស្ថានភាពដើមទេដែលគួរយកមកគិតក្នុងCBA។

## ដំណាក់កាលទី២៖ សម្រេចថាតើត្រូវគិតបន្ទុកចំណាយ និងផលចំណេញរបស់នរណា

សម្រាប់សំណើបញ្ញត្តិភាគច្រើន ការវាស់វែងបន្ទុកចំណាយ និងផលចំណេញជាតិ គឺសមរម្យជាងការវាស់វែងផលប៉ះពាល់អន្តរជាតិ។ ជាការអនុវត្ត អ្នកគួរគិតបន្ទុកចំណាយ និងផលចំណេញចំពោះមនុស្សដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា។

## ដំណាក់កាលទី៣៖ កំណត់ផលប៉ះពាល់ និងជ្រើសរើសខ្នាតស្ទង់នាករ

កំណត់ផលប៉ះពាល់ទាំងអស់របស់ជម្រើសនីមួយៗ។ វាមានសារៈសំខាន់ ដើម្បីកំណត់បន្ទុកចំណាយបន្ថែមនិងផល

ចំណេញបន្ថែមរបស់ជម្រើសនីមួយៗ ដែលពាក់ព័ន្ធនឹងស្ថានភាពដើម (ជាធម្មតានឹងកើតឡើងប្រសិនបើបទបញ្ញត្តិបច្ចុប្បន្ននៅតែបន្ត?)

មានសារៈប្រយោជន៍ពាក់ព័ន្ធនឹងស្ថានភាពដើមដែលគួរសម្លឹងមើលទៅមុខដោយទទួលស្គាល់ថា លិខិតបទដ្ឋានគតិយុត្តនឹងត្រូវបានអនុវត្តអាចខុសគ្នាពីស្ថានភាពបច្ចុប្បន្ន (អថេរសំខាន់អាចមានការផ្លាស់ប្តូរនៅពេលអនាគត មានន័យថា ស្ថានភាពបច្ចុប្បន្ន ឬស្ថានភាពពីមុន អាចមិនមានសារៈប្រយោជន៍ច្រើនទេ)។ គឺថាស្ថានភាពដើមមិនគួរសន្មតដ៏ងាយថានឹងមិនមានអ្វីផ្លាស់ប្តូរទេ មួយរយៈពេលក្រោយមក ការផ្លាស់ប្តូរដែលអាចត្រូវបានរំពឹងថានឹងកើតឡើង គួរត្រូវបានទទួលស្គាល់នៅពេលកំណត់ផលប៉ះពាល់ របស់ជម្រើសនីមួយៗ។

ឥទ្ធិពលទាំងអស់របស់សំណើបញ្ញត្តិកម្មមួយដែលត្រូវបានគេពិចារណាថា ជាការចង់បានរបស់អ្នករងផលប៉ះពាល់នោះ គឺជាផលចំណេញ។ ឥទ្ធិពលដែលគេមិនចង់បានទាំងអស់ គឺជាបន្ទុកចំណាយ។ CBA តម្រូវឲ្យអ្នកកំណត់វិធីជាក់លាក់ ដែលសំណើបញ្ញត្តិកម្មធ្វើឲ្យបុគ្គលមានភាពប្រសើរ ឬអាក្រក់ជាងមុន។

ការជ្រើសរើសសូចនាករ ដើម្បីវាស់វែងផលប៉ះពាល់ផ្អែកលើទិន្នន័យដែលមាន និងភាពងាយស្រួលគណនាចេញជាទឹកប្រាក់។ ឧទាហរណ៍ សំណើបញ្ញត្តិកម្មមួយអាចកាត់បន្ថយហានិភ័យនៃភាពមានគ្រោះថ្នាក់។ ផលប៉ះពាល់វិជ្ជមានអាចត្រូវបានវាស់វែងបាន តាមរយៈការកាត់បន្ថយចំនួនគ្រោះថ្នាក់។ ផលចំណេញពីការគេចផុតពីគ្រោះថ្នាក់ អាចត្រូវបានឲ្យតម្លៃជាដុល្លារ (មើលជំហានទី៥)។

## ជំណាក់កាលទី៤៖ ព្យាករណ៍ផលប៉ះពាល់របស់សំណើបញ្ញត្តិកម្មរហូតអស់សុពលភាព

ផលប៉ះពាល់គួរត្រូវបានកំណត់ជាបរិមាណតាមកាលវេលានីមួយៗ រហូតដល់សំណើបញ្ញត្តិកម្មអស់សុពលភាព។ កាលវេលាសរុបចាំបាច់ត្រូវតែវែងល្មម ដើម្បីគ្របដណ្តប់ឱ្យអស់នូវសក្តានុភាពនៃបន្ទុកចំណាយនិងផលចំណេញ។ ដោយសារតែមានភាពមិនប្រាកដប្រជាក្នុងការព្យាករណ៍បន្ទុកចំណាយនិងផលចំណេញរយៈពេលវែង ត្រូវប្រយ័ត្នប្រយែងនៅពេលធ្វើការវាយតម្លៃរយៈពេលវែង ជាឧទាហរណ៍សម្រាប់ពេលជាង២០ឆ្នាំជាដើម។ល។ (ទោះបីជាលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងបរិស្ថានខ្លះតម្រូវឲ្យប្រើប្រាស់ រយៈពេលវែងជាងក៏ដោយ)។

ការព្យាករណ៍ផលប៉ះពាល់នៅពេលអនាគត គឺមានការលំបាក។ ភាពមិនប្រាកដប្រជា អំពីលទ្ធផលចុងក្រោយ

របស់សំណើបញ្ញត្តិកម្មតែងតែកើតមានឡើង។ ការវាយតម្លៃភាពមិនប្រាកដប្រជា គួរមានស្តង់ដាសមាសភាពនៃការវាយតម្លៃលើសំណើបញ្ញត្តិកម្មសំខាន់ៗខ្លះ។ នេះមានន័យថាអ្នកធ្វើការវាយតម្លៃលើតម្លៃរំពឹងទុក និងអថេរនៃបន្ទុកចំណាយ និងផលចំណេញ ព្រមទាំងគិតពិចារណាពីហានិភ័យ។

CBA គួរបង្ហាញការប៉ាន់ស្មានដ៏ល្អបំផុតពីបន្ទុកចំណាយ និងផលចំណេញរំពឹងទុក រួមជាមួយនឹងការរៀបរាប់ពីភាពមិនប្រាកដប្រជាធំៗ ហើយត្រូវយកមកពិចារណាយ៉ាងម៉េច។ អ្នកត្រូវកំណត់ថា តើបន្ទុកចំណាយនិងផលចំណេញអាចនឹងប្រែប្រួលយ៉ាងម៉េច។ ឧទាហរណ៍ តើថ្លៃប្រែប្រួលយ៉ាងណា (ដូចជាការឡើងថ្លៃថាមពល ឬការកើនឡើងនៃប្រាក់ឈ្នួលជាក់ស្តែង) តើការប្រែប្រួលគួរឱ្យកត់សម្គាល់នូវផលចំណេញសុទ្ធ របស់សំណើបញ្ញត្តិកម្មយ៉ាងណា? ជាទូទៅ CBA មិនគួរសន្មតថា ផលចំណេញសុទ្ធសម្រាប់រយៈពេល១ឆ្នាំ ហើយនឹងនៅចំណេញដដែលៗនៅឆ្នាំបន្តទៀតនោះទេ។

ទោះជាវាមានការលំបាកក្នុងការព្យាករណ៍នូវអ្វីដែលជាឥទ្ធិពលរបស់សំណើបញ្ញត្តិកម្មក្នុងរយៈពេល១០ឆ្នាំ ឬ ២០ឆ្នាំខាងមុខក៏ដោយ ក៏ការសម្រេចចិត្តតម្រូវឲ្យមានការសន្មតខ្លះ។ CBA គួរធ្វើការសន្មតឲ្យមានតម្លាភាពនៅពេលអ្នកធ្វើការពិចារណា និងផ្តល់ហេតុផលនូវការសន្មតដោយបញ្ជាក់ពី

ការព្យាករណ៍ វានឹងធ្វើឲ្យកាន់តែប្រសើរនូវផែនការអនុវត្ត ហើយកំណត់បាននូវកិច្ចប្រឹងប្រែង ដែលធ្វើឲ្យការវិភាគកាន់តែល្អ។ វាជាដំណាក់កាលទី១ ក្នុងការដោះស្រាយភាពមិនប្រាកដប្រជាដែលសំណើបញ្ញត្តិកម្មអាចបង្កើតឡើង។

## ដំណាក់កាលទី៥៖ គិតជាទឹកប្រាក់ចំពោះផលប៉ះពាល់ (គ្នាប់ជាតម្លៃដុល្លារ)

ការប៉ាន់ស្មានតម្លៃដុល្លារសុទ្ធដែលចំណេញ និងខាតបង់របស់លិខិតបទដ្ឋានគតិយុត្តមួយ ចំពោះអ្នកពាក់ព័ន្ធទាំងអស់ គឺជាបេះដូងនៃCBA។ ការវាស់វែងបន្ទុកចំណាយ និងផលចំណេញជួនកាលអាចនិយាយបានថា ជាការគិតជាទឹកប្រាក់ចំពោះបន្ទុកចំណាយ និងផលចំណេញ។

ចំនួនទឹកប្រាក់ដែលបុគ្គលម្នាក់ៗនឹងត្រូវបង់ ដើម្បីទទួលបាន(ឬជៀសវាង) គឺជាការវាស់វែងតម្លៃមួយដែលផ្លាស់ប្តូរចំពោះពួកគេ។ តម្លៃអាចជាវិជ្ជមាន ឬអវិជ្ជមាន អាស្រ័យលើថាតើការផ្លាស់ប្តូរធ្វើឲ្យពួកគេល្អប្រសើរជាង ឬអាក្រក់ជាងមុន។ ការបន្ថែមតម្លៃដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ផ្តល់នូវឆន្ទៈសរុបរបស់សហគមន៍ក្នុងការចំណាយសម្រាប់ការផ្លាស់ប្តូរ។ ប្រសិនបើចំនួនសរុបមានលទ្ធផលវិជ្ជមាន នោះមានន័យថាការផ្លាស់ប្តូរគឺបានបង្កើនប្រសិទ្ធផល។ បន្ទុកចំណាយ និងផលចំណេញចំពោះមនុស្សទាំងអស់ត្រូវបានបន្ថែម ដោយ

មិនពាក់ព័ន្ធនឹងបុគ្គលនីមួយៗ ដែលមានមនុស្សម្នាក់ទទួលបាន១ដុល្លារ នោះនឹងមានមនុស្សម្នាក់ផ្សេងទៀតនឹងបាត់បង់១ដុល្លារ។

ការសន្មត "មួយដុល្លារគឺមួយដុល្លារ" អាចឲ្យមានការបែងចែកធនធានដែលត្រូវញែកចេញពីឥទ្ធិពលសមធម៌ ឬភាពខុសគ្នារវាងឥទ្ធិពលប្រសិទ្ធផល និងសមធម៌។ នោះមិនមានន័យថា ការពិចារណាពីការបែងចែកមិនសំខាន់ ឬធ្វើព្រងើយកន្តើយនោះទេ ។ វាមានន័យថា ពួកគេគួរពិចារណាជាផ្នែកដោយឡែកនៃការវិភាគទូទៅនៃសំណើបញ្ញត្តិកម្ម ដែលជាសំណួរអាចមានសារៈសំខាន់ជាងការវាយតម្លៃលើការបែងចែកធនធាន ក៏ប៉ុន្តែគួរត្រូវញែកចេញ។ ការដោះស្រាយបញ្ហាសមធម៌ត្រូវបាន ពិភាក្សាលម្អិតនៅផ្នែក "ការពិចារណាលើសមធម៌"។

តម្លៃដុល្លារអាចត្រូវបានប៉ាន់ស្មានពីការសង្កេត។ អ្នកអាចវាស់វែងតម្លៃដែលមនុស្សកំណត់លើអ្វីមួយ តាមការសង្កេតមើល តើពួកគេបង់ថ្លៃប៉ុន្មានចំពោះទំនិញ ឬសេវាជាក់លាក់ណាមួយនិងបរិមាណរបស់វា។ អត្តចរិកទីផ្សារបង្ហាញថា ការឲ្យតម្លៃរបស់មនុស្ស (ឬយ៉ាងហោចណាស់ក៏ជាការបង្ហាញផ្លូវដល់ពួកគេ)។ ឧទាហរណ៍ ប្រសិនបើអតិថិជនម្នាក់បង់៣.៥០ដុល្លារសម្រាប់កាហ្វេមួយពែង តម្លៃដែលពួកគេកំណត់លើ

កាហ្វេនោះ គឺយ៉ាងហោចណាស់៣.៥០ដុល្លារ (វាអាចច្រើនជាងនេះ)។

ទោះយ៉ាងណាក៏ដោយ ការគិតជាទឹកប្រាក់ ឬជាទូទៅជាបរិមាណ អាចមានការលំបាក ពីព្រោះផលប៉ះពាល់ជួនកាលមិនប្រាកដប្រជា ខ្លះមានការលំបាកកំណត់តម្លៃជាដុល្លារ ហើយខ្លះទៀតទាំងលំបាក ទាំងមិនច្បាស់លាស់ក្នុងការកំណត់តម្លៃជាដុល្លារ។ ទំនិញបរិស្ថាន ឬបទប្បញ្ញត្តិស្តីពីសុវត្ថិភាព គឺជាឧទាហរណ៍ល្អអំពីទំនិញ ដែលមានការលំបាកក្នុងការកំណត់តម្លៃជាដុល្លារ ដោយសារទំនិញទាំងនោះមិនមានតម្លៃនៅលើទីផ្សារ។ វិធីសាស្រ្តផ្សេងៗសម្រាប់ប៉ាន់ស្មានតម្លៃទំនិញដែលមិនមាននៅលើទីផ្សារ និងការពិចារណាពីភាពមិនប្រាកដប្រជានៅក្នុងCBA មានបញ្ជាក់ខាងក្រោមនៅក្នុងផ្នែក ″ការដោះស្រាយជាមួយបន្ទុកចំណាយ និងផលចំណេញដែលលំបាកក្នុងការកំណត់តម្លៃចំពោះការគណនា‶។

ការដែលផលប៉ះពាល់ខ្លះអាចមានការលំបាកខ្លាំងក្នុងការកំណត់បរិមាណជាដុល្លារ មិនប៉ះពាល់ដល់តម្លៃនៃការវិភាគតាមវិធីសាស្រ្តCBAទេ។ ក្នុងករណីបែបនេះ ការវិភាគតាមបែបគុណភាពលម្អិតជាការសមរម្យ ជំនួសឲ្យការកំណត់តម្លៃជាដុល្លារ។ ការវិភាគតាមបែបគុណភាព គួរមានការគាំទ្រដោយភស្តុតាង និងទិន្នន័យជាអតិបរមា ដើម្បីបង្កើនតម្លាភាពនៅក្នុង

របាយការណ៍ និងជួយអ្នកធ្វើសេចក្តីសម្រេចក្នុងការជ្រើសរើសជម្រើសណាមួយ។

## ជំណាក់កាលទី៦៖ បញ្ចុះតម្លៃចំពោះបន្ទុកចំណាយ និងផលចំណេញអនាគត ដើម្បីទទួលបានតម្លៃបច្ចុប្បន្ន

ហេតុអ្វីត្រូវបញ្ចុះតម្លៃ?

តម្រូវការបញ្ចុះតម្លៃផលប៉ះពាល់អនាគតអាចមានទស្សនៈវិស័យពីរ ដែលទស្សនៈវិស័យទាំងនេះផ្តោតលើចំណាយឱកាសនៃលំហូរសាច់ប្រាក់កំណត់ដោយលិខិតបទដ្ឋានគតិយុត្ត។ ទស្សនៈវិស័យទី១ ការសង្កេតទូទៅដែលបុគ្គលពេញចិត្តឲ្យតម្លៃមួយដុល្លារបច្ចុប្បន្ន ច្រើនជាងមួយដុល្លារនៅពេលអនាគត។ នេះគឺច្បាស់បំផុតនៅក្នុងហេតុការណ៍ដែលថា ធនាគារត្រូវការបង់ការប្រាក់នៃប្រាក់តម្កល់ ដើម្បីទាក់ទាញមនុស្សឲ្យសន្សំប្រាក់។ ការពេញចិត្តជាទូទៅសម្រាប់ការប្រើប្រាស់បច្ចុប្បន្នគឺត្រូវបានគេស្គាល់ថា "អត្រានៃពេលវេលាពេញចិត្ត" ហើយទាក់ទងនឹងផលប្រយោជន៍សេដ្ឋកិច្ចទាំងអស់ (និងបន្ទុកចំណាយ) មិនត្រឹមតែជាលក្ខណៈហិរញ្ញវត្ថុទេ។

ដោយសារបុគ្គលមិនព្រងើយកន្តើយរវាងលំហូរសាច់ប្រាក់នៅពេលវេលាខុសៗគ្នា លំហូរនោះមិនអាចប្រៀបធៀបដោយផ្ទាល់បានទេ។ ដើម្បីកំណត់លំហូរសាច់ប្រាក់ដែល

អាចប្រៀបធៀបដោយផ្ទាល់បាននៅក្នុងCBA បន្ទុកចំណាយ និងផលចំណេញនោះបានកើតឡើងនៅពេលអនាគត ចាំបាច់ត្រូវមានការបញ្ចុះតម្លៃដោយធៀបនឹងតម្លៃបច្ចុប្បន្ន។ នេះឆ្លុះបញ្ចាំងពីការពេញចិត្តរបស់សង្គម ដែលដាក់ឲ្យមានទម្ងន់ច្រើនលើការប្រើប្រាស់ដែលកើតឡើងឲ្យកៀកនឹងបច្ចុប្បន្ន។

ទស្សនៈវិស័យទី២ គឺថាលំហូរបន្ទុកចំណាយនិងផលចំណេញ កើតចេញពីលិខិតបទដ្ឋានគតិយុត្តក៏មានចំណាយឱកាសសម្រាប់ការវិនិយោគ។ នៅពេលលិខិតបទដ្ឋានគតិយុត្តដាក់បន្ទុកចំណាយលើបុគ្គល ឬធុរកិច្ច បន្ទុកចំណាយនោះនឹងត្រូវផ្តល់មូលនិធិឲ្យវិញតាមរបៀបខ្លះ។ ការផ្តល់មូលនិធិនេះដាក់បន្ទុកចំណាយលើភាគីរងផលប៉ះពាល់ តាមរយៈការប្រាក់ដែលត្រូវបង់ចំពោះការខ្ចីលុយ ឬមូលនិធិនោះបាត់ទៅនៅពេលមិនបានប្រើប្រាស់សម្រាប់គោលបំណងផ្សេង។

ហេតុដូច្នេះ លិខិតបទដ្ឋានគតិយុត្តនឹងមានប្រយោជន៍នៅពេលវាផ្តល់ផលចំណេញច្រើនជាងបន្ទុកចំណាយដល់សង្គម ឬផលចំណេញអាចទទួលបាននៅពេលប្រើប្រាស់មូលនិធិចំគោលដៅ។ ដោយអនុវត្តអត្រាបញ្ចុះតម្លៃចំពោះលំហូរសាច់ប្រាក់ អត្រាសាច់ប្រាក់ត្រលប់ត្រូវពិចារណានៅក្នុងការគណនាតម្លៃបច្ចុប្បន្នសុទ្ធ។

វិធីសាស្រ្តបានបង្ហាញថា តម្រូវការក្នុងការបញ្ចុះតម្លៃលំហូរសាច់ប្រាក់អនាគតអាចជាចំណាយឱកាសនៃលំហូរសាច់ប្រាក់។ ថាតើនេះជាបន្ទុកចំណាយនៃការពន្យាពេលប្រើប្រាស់ ឬជម្រើសឱកាសវិនិយោគបានបាត់បង់។ ដោយសារបន្ទុកចំណាយ និងផលចំណេញរបស់សំណើបញ្ញត្តិកម្មភាគច្រើនមានរយៈពេលវែង។ ហើយតម្លៃរបស់វាអាស្រ័យលើពេលវេលាដែលទទួលបាន ការបញ្ចុះតម្លៃមានសារៈសំខាន់នៅក្នុងCBA។

អត្រាដែលបំប្លែងតម្លៃអនាគតទៅជាតម្លៃបច្ចុប្បន្នត្រូវបានគេស្គាល់ថាជាអត្រាបញ្ចុះតម្លៃ។ ប្រសិនបើអត្រាបញ្ចុះតម្លៃនៅថេរត្រង់ចំណុច $r$ ភាគរយក្នុង១ឆ្នាំ ផលចំណេញ $B_t$ ដុល្លារបានទទួលនៅឆ្នាំ $t$ មានតម្លៃ $B_t /(1+r)^t$ នាពេលបច្ចុប្បន្ន។ ប្រអប់ទី១ ផ្តល់ឧទាហរណ៍ពីរបៀបគណនាតម្លៃបច្ចុប្បន្នសុទ្ធ។ បញ្ជីឯកសារយោងដែលផ្តល់ការណែនាំលម្អិតមានភ្ជាប់នៅទំព័រចុងក្រោយនៃមគ្គុទេសក៏នេះ។

## ***ការពិចារណាពីអតិផរណា***

អតិផរណា គឺជាហេតុផលមួយទៀតដែលថាមួយដុល្លារនាពេលអនាគតមានតម្លៃតិចជាងមួយដុល្លារនាពេលបច្ចុប្បន្ន។ ការកើនឡើងជាទូទៅនៃកម្រិតថ្លៃមានន័យថា មួយដុល្លារនាពេលអនាគតអាចទិញបានទំនិញតិចជាង។ អ្នកវិភាគCBA

មានជម្រើស ថាតើត្រូវបញ្ចូលលំហូរសាច់ប្រាក់អនាគតតាមតម្លៃជាក់ស្តែងនាពេលអនាគត (តម្លៃមានតែនាម) ឬតម្លៃដុល្លារបច្ចុប្បន្ន (តម្លៃពិត)។ ទោះបីជាយ៉ាងណាលំហូរសាច់ប្រាក់ទាំងអស់ចាំបាច់ត្រូវបំប្លែងទៅជាដុល្លារបច្ចុប្បន្នដែលអាចប្រៀបធៀបបាននៅក្នុងCBA ជាធម្មតាវិធីសាស្រ្តក្រោយនេះមានភាពសាមញ្ញបំផុត។

**ប្រអប់ទី១៖ ការគណនាតម្លៃបច្ចុប្បន្នសុទ្ធ**

ដើម្បីកំណត់តម្លៃបច្ចុប្បន្នសុទ្ធ(NPV)នៃជម្រើសមួយ ការចំណាយ និងផលចំណេញត្រូវតែកំណត់ចំនួនសម្រាប់រយៈពេលដែលបានរំពឹងទុកនៃសំណើបញ្ញត្តិកម្ម។

តម្លៃបច្ចុប្បន្នសុទ្ធគឺត្រូវបានគណនាជា៖

$$NPV = (B_t-C_t)/(1+r)^t$$

តម្លៃបច្ចុប្បន្នសុទ្ធ = $(B_t-C_t)/(1+r)^t$

ដែល $B_t$ = ផលចំណេញកើតឡើងនៅពេល t

$C_t$ = ការចំណាយកើតឡើងនៅពេល t

r = អត្រាបញ្ចុះតម្លៃ

t = ជាឆ្នាំ

T = ចំនួនឆ្នាំកន្លងដែលការចំណាយ ឬផលចំណេញ

នាថ្ងៃអនាគតត្រូវបានរំពឹងទុកឱ្យកើតមាន (ឆ្នាំនេះគឺជាឆ្នាំ ០)

ចូរពិចារណាពីជម្រើសដែលនឹងតម្រូវឲ្យក្រុមហ៊ុន ដើម្បីតម្លើងឧបករណ៍ថ្មីដើម្បីកាត់បន្ថយការបំពុលបរិយាកាស។ឧបករណ៍នេះមានតម្លៃ៥លានដុល្លារអាមេរិកដើម្បីតម្លើង និងដំណើរការសម្រាប់៤ឆ្នាំដូចខាងក្រោមនេះ។ ការចំណាយ ដំណើរការ( ការថែទាំប្រចាំឆ្នាំ) ចំពោះក្រុមហ៊ុនគឺ១លានដុល្លារអាមេរិកក្នុងមួយឆ្នាំ( ក្នុងតម្លៃស្ថិតថេរដាក់លាក់)។ ផលចំណេញប៉ាន់ស្មាន ថាទទួលបាន ៣ លានដុល្លារក្នុងមួយឆ្នាំ (ក្នុងតម្លៃស្ថិតថេរដាក់លាក់)។ អត្រាបញ្ចុះតម្លៃគឺ ៣%, ៧% និង១០%។

| | ការចំណាយ ($C_t$) | ផលចំណេញ ($B_t$) | ផលចំណេញសុទ្ធ ($B_t$-$C_t$) | តម្លៃបច្ចុប្បន្នសុទ្ធ (NPV) 3% | 7% | 10% |
|---|---|---|---|---|---|---|
| Year 0 | 5 | 0 | -5 | -5.00 | -5.00 | -5.00 |
| Year 1 | 1 | 3 | 2 | 1.94 | 1.87 | 1.82 |
| Year 2 | 1 | 3 | 2 | 1.89 | 1.75 | 1.65 |
| Year 3 | 1 | 3 | 2 | 1.83 | 1.63 | 1.50 |
| Year 4 | 1 | 3 | 2 | 1.78 | 1.53 | 1.37 |
| **តម្លៃបច្ចុប្បន្នសុទ្ធចំពោះសំណើ** | | | | **2.43** | **1.77** | **1.34** |

CBA ប៉ាន់តម្លៃដែលមនុស្សកំណត់សម្រាប់លទ្ធផលផ្សេងៗ ជាពិសេសទៅតាមឆន្ទៈពួកគេហ៊ានចំណាយដែលបង្ហាញតាមឥរិយាបថទីផ្សាររបស់ខ្លួន។ ដូច្នេះវិធីសាស្ត្រដែលពេញចិត្តគឺផ្អែកទៅលើអត្រាបញ្ចុះតម្លៃ អត្រាការប្រាក់តាមទីផ្សារ ដែលចង្អុលបង្ហាញពីតម្លៃបច្ចុប្បន្នដែលគេកំណត់ធៀបនឹងផលចំណេញសុទ្ធនាថ្ងៃអនាគត។ អត្រាការប្រាក់ទីផ្សារកំណត់ថ្លៃបាត់ឱកាស នៃចំនួនមូលធនដែលបានប្រើប្រាស់

ដោយសំណើលិខិតបទដ្ឋានគតិយុត្តរបស់រដ្ឋាភិបាល - មានន័យថានោះគឺជាអ្វីដែលមូលធនអាចយកទៅប្រើប្រាស់តាមជម្រើសផ្សេងទៀត។

អត្រាបញ្ចុះតម្លៃត្រឹមត្រូវនៅតែមានភាពមិនប្រាកដប្រជាសម្រាប់ប្រើប្រាស់ចំពោះសំណើបញ្ញត្តិកម្ម។ យើងមិនប្រាកដថាមូលធនអាចយកទៅប្រើប្រាស់តាមជម្រើសអ្វីផ្សេងទៀតហើយមូលធនអ្វីខ្លះអាចផលិតចេញបានតាមរយៈការប្រើប្រាស់ទាំងនោះ។

## *អត្រាបញ្ចុះតម្លៃសម្រាប់ការអន្តរាគមន៍បញ្ញត្តិកម្ម*

CBA គួរកំណត់អត្រាបញ្ចុះតម្លៃ ″មធ្យម″ជាក់ស្តែងមួយ។ ជាមួយនឹងការផ្លាស់ប្តូរមិនប្រាកដប្រជា យើងគួរធ្វើការវិភាគភាពប្រែប្រួល (សូមមើលនៅខាងក្រោមសម្រាប់ព័ត៌មានបន្ថែមស្តីពីការវាស់វែងភាពប្រែប្រួល) ដូច្នេះបន្ថែមពីលើអត្រាបញ្ចុះតម្លៃមធ្យម តម្លៃបច្ចុប្បន្នសុទ្ធគួរត្រូវបានគណនាជាមួយអត្រាបញ្ចុះតម្លៃទាបជាងនិងខ្ពស់ជាងជាក់ស្តែង។ ប្រសិនបើរកឃើញសញ្ញាផ្លាស់ប្តូរតម្លៃបច្ចុប្បន្នសុទ្ធ ការវិភាគភាពប្រែប្រួលបង្ហាញឲ្យឃើញថា ជម្រើសនៃអត្រាបញ្ចុះតម្លៃគឺមានសារៈសំខាន់។ ព័ត៌មាននេះត្រូវបញ្ជាក់ក្នុងរបាយការណ៍សង្ខេបCBA ពីព្រោះវាជាការរំលឹកសំខាន់សម្រាប់ការវិភាគនេះ។

ឯកសារយោងជាច្រើននៅផ្នែកចុងក្រោយនៃមគ្គុទេសក៍នេះផ្ដល់ការពិភាក្សាពិស្ដារជាច្រើនជុំវិញបញ្ហាទាក់ទិននឹងអត្រាបញ្ចុះតម្លៃ និងអត្រាបញ្ចុះតម្លៃបច្ចុប្បន្នជាក់លាក់ដែលអាចប្រើប្រាស់បានក្នុង CBA។

## ដំណាក់កាលទី៧៖ គណនាតម្លៃបច្ចុប្បន្នសុទ្ធរបស់ជម្រើសនីមួយៗ

តម្លៃបច្ចុប្បន្នសុទ្ធ(NPV)នៃជម្រើសមួយស្មើនឹងតម្លៃបច្ចុប្បន្ននៃផលចំណេញដក តម្លៃបច្ចុប្បន្ននៃបន្ទុកចំណាយ៖

NPV = PV (B) – PV(C)

ប្រសិនបើ NPV ជាសញ្ញាបូក (+) សំណើនេះបង្កើននូវប្រសិទ្ធភាព។ ប្រសិនបើ NPV ជាសញ្ញាដក (-) សំណើនេះគឺមិនមានប្រសិទ្ធិភាព។ ប្រសិនបើបន្ទុកចំណាយនិងផលចំណេញ ទាំងអស់មិនអាចកំណត់តម្លៃជាទឹកប្រាក់ អ្នកគួរតែស្វែងយល់ថា ហេតុអ្វីផលចំណេញនិងបន្ទុកចំណាយមិនមែនជាសាច់ប្រាក់មានទំហំធំឬតូចធៀបទៅនឹងផលប៉ះពាល់ដែលអាចគិតជាសាច់ប្រាក់។

## ដំណាក់កាលទី៨៖ ធ្វើការវិភាគភាពប្រែប្រួល

ផលប៉ះពាល់ដែលបានព្យាករណ៍ទុក និងការប៉ាន់តម្លៃជាទឹកប្រាក់ត្រឹមត្រូវអាចមានភាពមិនប្រាកដប្រជាដ៏ធំ។ ការវិភាគ

ភាពប្រែប្រួលផ្តល់នូវព័ត៌មានអំពីរបៀបដែលអថេរផ្សេងគ្នាប្រែប្រួលនឹងជះឥទ្ធិពលទៅលើបន្ទុកចំណាយនិងផលចំណេញរួមនៃសំណើបញ្ញត្តិកម្ម។ វាបង្ហាញពីរបៀបដែលផលចំណេញសុទ្ធដែលបានព្យាករណ៍ទុកប្រែប្រួលទៅតាមអថេរមិនច្បាស់លាស់ដែលមានតម្លៃផ្សេងៗគ្នា និងការផ្លាស់ប្តូរនៃការសន្មត។ វាពិសោធថាតើភាពមិនប្រាកដប្រជាចំពោះតម្លៃនៃបញ្ហាអថេរជាក់លាក់ និងកំណត់នូវការសន្មតដ៏សំខាន់។

ប្រសិនបើការវិភាគភាពប្រែប្រួលគឺមានផលប្រយោជន៍ដល់អ្នកធ្វើការសម្រេច វាត្រូវការអនុវត្តដោយប្រព័ន្ធនិងពន្យល់យ៉ាងច្បាស់លាស់។ វិធីសាស្ត្រទូទៅចំពោះការវិភាគភាពប្រែប្រួលរួមមានដូចខាងក្រោមនេះ៖

- ការវិភាគករណីល្អបំផុត/អាក្រក់បំផុត៖ ករណីមូលដ្ឋានផ្តល់នូវតម្លៃល្អបំផុតចំពោះអថេរដើម្បីផ្តល់ការប៉ាន់តម្លៃផលចំណេញសុទ្ធដែលគិតថាល្អបំផុត។ សេណារីយ៉ូអាក្រក់ ឬទុទិដ្ឋិនិយមបំផុតគឺកំណត់ តម្លៃអន់ជាងគេចំពោះអថេរ។ ប្រសិនបើសេណារីយ៉ូទុទ្ធិដ្ឋិនិយមផ្តល់នូវ NPV នៅក្រោមសូន្យ អ្នកនឹងត្រូវអង្កេតមើលធាតុផ្សំសំខាន់ៗដែលពាក់ព័ន្ធនឹងតម្លៃនៃសំណើបញ្ញត្តិកម្ម ដោយប្រើប្រាស់បច្ចេកទេសពីរដូចខាងក្រោម។

*ការវិភាគភាពប្រែប្រួលដោយផ្នែក* ត្រួតពិនិត្យពីរបៀបផ្លាស់ប្តូរផលចំណេញសុទ្ធទៅតាមការប្រែប្រួលអថេរ

មួយសំណុំ (ដោយគិតថាអថេរផ្សេងទៀតនៅដដែល)។ វាគួរតែប្រើប្រាស់សម្រាប់អថេរសំខាន់បំផុតឬមិនជាក់លាក់ ដូចជាការប៉ាន់តម្លៃនៃបន្ទុកចំណាយប្រតិបត្តិតាមការព្យាករណ៍នៃផលចំណេញ និងអត្រាបញ្ចុះតម្លៃ។

ការកំណត់តម្លៃផ្សេងគ្នាចំពោះ "ទ្រព្យអរូបី" គឺមានសារៈសំខាន់ជាពិសេសនៅពេលដែលតម្លៃសន្មតមានភាពចម្រូងចម្រាស។ ការវិភាគភាពប្រែប្រួលដោយផ្នែកផ្តល់ព័ត៌មានកាន់តែច្បាស់លាស់ដល់អ្នកធ្វើសេចក្តីសម្រេចពីរបៀបដែលលទ្ធផល CBA រងឥទ្ធិពលដោយអថេរមិនជាក់លាក់តាមកម្រិតនិងតម្លៃផ្សេងៗ។ ប្រសិនបើអ្នករកឃើញថាការកំណត់ប៉ារ៉ាម៉ែត្រផ្សេងៗមានឥទ្ធិពលខ្លាំងលើផលចំណេញសុទ្ធនៃសំណើបញ្ញត្តិកម្ម យើងត្រូវយកចិត្តទុកដាក់អំពីតម្លៃមិនប្រាកដប្រជារបស់វា ។

*ការវិភាគភាពប្រែប្រួល* **Monte Carlo** បង្កើតក្រាហ្វិចនៃខ្សែកោង នៃផលចំណេញសុទ្ធដោយទាញយកការសន្មតឬតម្លៃប៉ារ៉ាម៉ែត្រសំខាន់ៗពីខ្សែកោងនៃប្រូបាប៊ីលីតេ (ចូរមើល Boardman et al. 2010, pp. 181–184) ។ ទោះបីនេះគឺជាវិធីសាស្ត្រស្ថិតិទំនើបសម្រាប់ការវិភាគភាពប្រែប្រួល យើងត្រូវយកចិត្តទុកដាក់ក្នុងការកំណត់យកការសន្មតដែលសមហេតុផល និងសមរម្យ អំពីខ្សែកោងនៃប្រូបាប៊ីលីតេដែលត្រូវបានសន្មត។

ប្រសិនបើសញ្ញា(+ ឬ - ) នៃផលចំណេញសុទ្ធមិនផ្លាស់ប្តូរបន្ទាប់ពីការពិចារណាតាមសេណារីយ៉ូមួយសំណុំ យើងអាចនឹងមានទំនុកចិត្តថាសំណើបញ្ញត្តិកម្មមានឥទ្ធិពលប្រសិទ្ធភាព។

## ដំណាក់កាលទី៩៖ ធ្វើសេចក្តីសន្និដ្ឋាន

អ្នកគួរតែសង្ខេបលទ្ធផលនៃCBA។ ជម្រើសដែលទទួលបានផលចំណេញខ្ពស់បំផុតគួរតែជាជម្រើសដែលអាចផ្តល់ជាអនុសាសន៍ ។ ដោយហេតុថា NPV គឺជាតម្លៃព្យាករណ៍ជាមធ្យម ហើយការវិភាគភាពប្រែប្រួលដែលអាចនឹងណែនាំជម្រើសផ្សេងដែលមាន NPV ធំបំផុតគឺមិនប្រាកដថា ជាជម្រើសល្អបំផុតនៅគ្រប់កាលៈទេសៈទាំងអស់នោះទេ។ ឧទាហរណ៍ អ្នកអាចនឹងមានទំនុកចិត្តបន្ថែមទៀតក្នុងការផ្តល់អនុសាសន៍ជម្រើសដែលមានតម្លៃផលចំណេញសុទ្ធទាបជាងតម្លៃរំពឹងទុក ប៉ុន្តែវាជាជម្រើសដែលកាត់បន្ថយលទ្ធភាពដាក់បន្ទុកចំណាយសុទ្ធសំខាន់នៅលើសហគមន៍ ("ហានិភ័យអវិជ្ជមាន"តិចជាង)។

ការសន្និដ្ឋានរបស់អ្នកគួរតែរួមបញ្ចូលទាំងពេលវេលាដែលប៉ាន់តម្លៃបន្ទុកចំណាយ, ផលចំណេញនិងអត្ថប្រយោជន៍សុទ្ធ, NPV របស់ខ្លួន, អត្រាបញ្ចុះតម្លៃដែលបានប្រើ, ព័ត៌មានអំពីភាពប្រែប្រួលនៃផលប៉ះពាល់ដែលបានប៉ាន់ស្មានចំពោះការសន្មតផ្សេងៗ ,បញ្ជីនៃការសន្មតដែលបានកំណត់និងរបៀបប៉ាន់ស្មានបន្ទុកចំណាយនិងផលចំណេញ ។

## ការដោះស្រាយជាមួយបន្ទុកចំណាយ និងផលចំណេញដែលលំបាកកំណត់ជាតម្លៃចំពោះការគណនា

នៅពេលមានសំណើប្រើប្រាស់និងផលិតទំនិញលក់នៅលើទីផ្សារ ការប៉ាន់ស្មានបន្ទុកចំណាយ និងផលចំណេញក្នុងករណីជាច្រើន វាមានភាពងាយស្រួលច្រើន និងត្រូវបានគ្របដណ្តប់នៅក្នុងមគ្គុទេសក៏CBAដែលមានស្រាប់។

ទោះជាយ៉ាងណាក៏ដោយ ជាញឹកញាប់វាមានការលំបាកក្នុងការកំណត់និងវាស់វែងឥទ្ធិពលរបស់សំណើបញ្ញត្តិកម្ម ជាពិសេសនៅពេលមានផលប៉ះពាល់ដល់ទំនិញដែលមិនធ្វើពាណិជ្ជកម្មនៅលើទីផ្សារ ដូចជាកម្រិតបំពុលបរិស្ថានឬភាពអាចទទួលបាននូវទិដ្ឋភាពធម្មជាតិដ៏ស្រស់ត្រកាល។

បន្ទុកចំណាយ និងផលចំណេញអាចមានការលំបាកក្នុងការកំណត់តម្លៃជាដុល្លារ ពីព្រោះទំហំនៃផលប៉ះពាល់មិនអាចដឹងមុន ឬមិនប្រាកដប្រជា ឬពីព្រោះវាពិបាកកំណត់ជាសាច់ប្រាក់ ទោះបីជាផលប៉ះពាល់នោះត្រូវបានគេដឹងក៏ដោយ។ ឧទាហរណ៍ រួមមាន ការគិតគូរដល់បញ្ហាបរិស្ថាន សង្គម និងវប្បធម៌ ផលប៉ះពាល់តំបន់ បញ្ហាសុខភាព សុវត្ថិភាពសាធារណៈ និងការពារជាតិ។

វាមានសារៈសំខាន់ដែលអ្នកត្រូវកំណត់ និងរៀបរាប់បន្ទុកចំណាយ និងផលចំណេញទាំងអស់។ អ្នកគួរកំណត់ជាបរិមាណនូវបន្ទុកចំណាយនិងផលចំណេញឲ្យបានច្រើនតាមតែអាចធ្វើបាន។ នៅពេលដែលការវាយតម្លៃមានភាពមិនច្បាស់លាស់ ការវិភាគភាពប្រែប្រួលគួរត្រូវបានប្រើ ដើម្បីធ្វើការសាកល្បងថាតើតម្លៃប្រែប្រួលយ៉ាងដូចម្ដេច ដែលអាចប៉ះពាល់ដល់លទ្ធផលនៃការវិភាគ។

ប្រសិនបើផលប៉ះពាល់មិនអាចកំណត់ជាតម្លៃបានទេ វាគួរតែត្រូវបានកំណត់ជាបរិមាណដែលមិនមែនជាទឹកប្រាក់។ ឧទាហរណ៍ លិខិតបទដ្ឋានគតិយុត្តមួយដើម្បីកាត់បន្ថយការបំពុលបរិស្ថាន អាចកំណត់ជាបរិមាណនូវការកាត់បន្ថយការបញ្ចេញឧស្ម័នពុល។ ការកំណត់ជាបរិមាណត្រូវសំដៅសម្រាប់បញ្ជាក់បញ្ហា ដូចជាការសន្មតអនុវត្តចំពោះការកំណត់ឥទ្ធិពលផលប៉ះពាល់ក្នុងសហគមន៍ (ដូចជា ចំនួនមនុស្សត្រូវរងផលប៉ះពាល់ និងរងផលប៉ះពាល់យ៉ាងដូចម្ដេច) និងភាពអាចកើតមានឡើងនៃផលប៉ះពាល់ពេញលេញ។ នៅពេលដែលផលប៉ះពាល់មិនអាចកំណត់ជាតម្លៃបាន គួរផ្ដល់ហេតុផលឲ្យបានច្បាស់លាស់។

ដំណើរនៃការខិតខំប្រឹងប្រែង ដើម្បីរៀបរាប់ និងវាស់វែងបន្ទុកចំណាយ និងផលចំណេញគឺមានតម្លៃដោយខ្លួនវា។

ដោយពិនិត្យនូវអ្វីដែលត្រូវកំណត់បន្ទុកចំណាយនិងផលចំណេញ និងការប្រែប្រួលរបស់វាកើតឡើងយ៉ាងណា អ្នកគួរពិចារណាវិធីសាស្ត្រផ្សេងៗ និងកំណត់វិធីសាស្ត្រដែលល្អបំផុតដើម្បីសម្រេចគោលបំណងអរូបី។ ថាតើគោលនយោបាយជាវិធីល្អបំផុតក្នុងការសម្រេចបានលទ្ធផល ឬលទ្ធផលដែលល្អជាងអនុវត្តចំពោះការកំណត់ឥទ្ធិពល ត្រូវបានបង្កើតឡើងដោយជម្រើសផ្សេងៗ? សូម្បីតែការរៀបរាប់តាមបែបគុណភាពរបស់អ្នកចូលចិត្តបរិយាយ និងអ្នកមិនចូលចិត្តបរិយាយពាក់ព័ន្ធជាមួយសកម្មភាពដែលត្រូវបានគិតទុក ក៏អាចមានប្រយោជន៍ដែរ។

ឧបករណ៍ជាច្រើនត្រូវបានអភិវឌ្ឍ ដើម្បីជួយប៉ាន់ស្មានតម្លៃនៃបន្ទុកចំណាយ និងផលចំណេញនៅពេលមិនមានព័ត៌មានទីផ្សារច្បាស់លាស់ រួមមាន បច្ចេកទេសបង្ហាញពីការពេញចិត្ត និងបច្ចេកទេសកំណត់ការពេញចិត្ត។ សូមមើល Boardman et al. (2010) or Commonwealth of Australia (2006) for more information។

## *បច្ចេកទេសបង្ហាញពីការពេញចិត្ត*

បច្ចេកទេសបង្ហាញពីការពេញចិត្តធ្វើការប៉ាន់ស្មានតម្លៃពីការសង្កេតឥរិយាបថនិងទំនាក់ទំនងទីផ្សារ។ នៅពេលបុគ្គលទិញទំនិញនៅលើទីផ្សារ ថ្លៃដែលត្រូវបង់បង្ហាញពីព័ត៌មាន

អំពីតម្លៃដែលបានដាក់នៅលើទំនិញនោះ។ គោលគំនិតនេះមានប្រយោជន៍ សម្រាប់វាស់វែងតម្លៃទីផ្សារមួយចំនួនធំ កិច្ចអន្តរាគមន៍នៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងទំនិញដែលមិនធ្វើពាណិជ្ជកម្មដោយផ្ទាល់នៅលើទីផ្សារ ឬទីផ្សារមិនផ្តល់សញ្ញាដែលគួរឲ្យទុកចិត្តបាន ដែលជាលទ្ធផលនៃបរាជ័យទីផ្សារមួយឬច្រើន។ ក្នុងករណីនេះ ការប៉ាន់ស្មានតម្លៃដែលត្រូវបានបញ្ចូលក្នុងCBA នឹងតម្រូវឲ្យអ្នកពិចារណាបច្ចេកទេសវាយតម្លៃមិនតាមទីផ្សារ។

បច្ចេកទេសទាំងនេះជាញឹកញាប់តម្រូវឲ្យប្រើប្រាស់ទីផ្សារជំនួស ដើម្បីផ្តល់ព័ត៌មានស្តីពីតម្លៃរបស់ទំនិញដែលមិនមានលក់នៅលើទីផ្សារ។ នៅពេលទំនិញស្រដៀងគ្នាដែលត្រូវបានគេធ្វើពាណិជ្ជកម្មនៅលើទីផ្សារ ថ្លៃរបស់វានឹងត្រូវបានគេយកធ្វើជាសំអាង។ ឧទាហរណ៍ ព័ត៌មានអំពីផលចំណេញពីការផ្តល់សេវាដឹកជញ្ជូនសាធារណៈដោយឥតគិតថ្លៃ អាចប្រមូលព័ត៌មានពីអ្នកធ្វើដំណើរនៅក្នុងក្រុងណាមួយដែលពលរដ្ឋបង់ថ្លៃសម្រាប់សេវាកម្មនេះ។

លិខិតបទដ្ឋានគតិយុត្តដែលមានបំណងកាត់បន្ថយលទ្ធភាពនៃព្រឹត្តិការណ៍អវិជ្ជមានដែលកើតឡើងអាចត្រូវបានកំណត់តម្លៃតាមការវិភាគឆន្ទៈបង់ថ្លៃរបស់បុគ្គលម្នាក់ៗ ដើម្បីជៀសវាងនូវព្រឹត្តិការណ៍នោះ។ ឧទាហរណ៍ លិខិតបទដ្ឋាន

គតិយុត្តពាក់ព័ន្ធនឹងសុខភាព និងសុវត្ថិភាព តែងតែប៉ាន់ស្មានតម្លៃនៃស្ថិតិជីវិត។ តម្លៃនេះជាញឹកញាប់ត្រូវបានប៉ាន់ស្មានដោយការវិភាគចំណាយលើឧបករណ៍សុវត្ថិភាពចាប់ផ្សេងពោងសុវត្ថិភាពរថយន្ត និងឧបករណ៍ផ្សេងទៀតដែលមនុស្សទិញ ដើម្បីកាត់បន្ថយលទ្ធភាពពីការស្លាប់ដោយគ្រោះថ្នាក់ទាំងអស់នោះ។

ក្នុងករណីខ្លះ "ថ្លៃ" ដែលបានបង់សម្រាប់ទំនិញមួយអាចមិនមែនជាទូទាត់ជាក់ស្តែងក្រដាសប្រាក់ទេ ប៉ុន្តែជំនួសមកវិញគឺវាឆ្លុះបញ្ចាំងពីកិច្ចប្រឹងប្រែងនិងការចំណាយរបស់បុគ្គលដើម្បីប្រើប្រាស់ទំនិញ។ ការចំណាយនេះអាចត្រូវបានប្រើប្រាស់ ដើម្បីប៉ាន់ស្មានតម្លៃរបស់ទំនិញមួយនៅពេលគ្មានវត្តមានទីផ្សារ។ ឧទាហរណ៍ តម្លៃនៃទស្សនៈកិច្ចនៅកន្លែងតាំងរូបឬសារមន្ទីរអាចត្រូវបានប៉ាន់ស្មាន ដោយការវិភាគចំណាយធ្វើដំណើររបស់អ្នកទេសចរ និងថ្លៃបាត់ឱកាសនៃពេលវេលារបស់គេដែលគេអាចធ្វើអ្វីផ្សេងទៀត។

## *បច្ចេកទេសកំណត់ការពេញចិត្ត*

នៅក្នុងស្ថានភាពខ្លះ មិនអាចប្រើប្រាស់បច្ចេកទេសបង្ហាញការពេញចិត្តបានទេ។ ករណីទាំងនេះជាធម្មតាកើតឡើងនៅពេលទំនិញមួយមិនត្រូវបានគេប្រើប្រាស់ច្រើនទេ ក៏ប៉ុន្តែវានៅតែមានតម្លៃ។ ក្នុងករណីបែបនេះព័ត៌មានអំពីឆន្ទៈ

របស់មនុស្សក្នុងការបង់ថ្លៃនៅតែទទួលបានដោយគ្រាន់តែសួរពួកគេឱ្យកំណត់ពីការពេញចិត្ត។ បច្ចេកទេសកំណត់ការពេញចិត្តផ្អែកលើការអង្កេត ដើម្បីទទួលបានព័ត៌មានអំពីថាតើមនុស្សកំណត់តម្លៃបន្ទុកចំណាយ និងផលចំណេញយ៉ាងដូចម្តេច? ការធ្វើអង្កេតនេះ ហៅថា ការអង្កេត "ការវាយតម្លៃជាយថាហេតុ"។

ការអង្កេតមួយប្រហែលជាវិធីតែមួយប៉ុណ្ណោះក្នុងការប្រមូលព័ត៌មានអំពីតម្លៃមិនប្រើប្រាស់ ដែលមនុស្សម្នាក់បានឲ្យតម្លៃលើធនធានមួយ ឬសកម្មភាពមួយ ទោះបីជាពួកគេមិនអាចប្រើប្រាស់ដោយផ្ទាល់ ឬចូលរួមក៏ដោយចុះ។ ឧទាហរណ៍មនុស្សប្រហែលជាអាចមានឆន្ទៈរក្សាទីរហោឋាន ពីព្រោះពួកគេឲ្យតម្លៃដោយដឹងថាមានទីលំនៅឋានធម្មជាតិខ្លះសម្រាប់ពពួកសត្វកម្រ។

Boardman et al. (2010, pp. 369–402) កំណត់ពីរបៀបដើម្បីអង្កេតវាយតម្លៃជាយថាហេតុ និងគូសបញ្ជាក់បញ្ហាខ្លះជាមួយនឹងបច្ចេកទេស។

គំរូជម្រើសគឺជាវិធីសាស្ត្រអង្កេតមួយផ្សេងទៀត ដែលអាចមានប្រយោជន៍ នៅពេលផលចំណេញបានពីសំណើបញ្ញត្តិកម្មមានលក្ខណៈសម្បត្តិច្រើន និងជម្រើសផ្តល់នូវការ

គួបផ្សំខុសៗគ្នារបស់លក្ខណៈសម្បត្តិទាំងនោះ។ ពិនិត្យដោយ OECD (2006; ទំព័រ 125–143) ។

ដើម្បីបន្ថែមអត្ថប្រយោជន៍ដល់CBA ការសិក្សាលើការកំណត់ការពេញចិត្តគួរស្វែងរកការប៉ាន់ស្មានឆន្ទៈក្នុងការបង់ថ្លៃពីមនុស្សដែលមានព័ត៌មានគ្រប់គ្រាន់។

ឧទាហរណ៍ ប្រសិនបើការសិក្សាគំរូជម្រើសព្យាយាមបង្កើតឡើងនូវឆន្ទៈក្នុងការបង់ថ្លៃរបស់សហគមន៍សម្រាប់លិខិតបទដ្ឋានគតិយុត្ត ដើម្បីកាត់បន្ថយហានិភ័យបរិស្ថានពិសេសណាមួយ វាមានសារៈសំខាន់ដែលអ្នកចូលរួមក្នុងការសិក្សា មានចម្លើយរបស់ពួកគេផ្អែកទៅលើព័ត៌មានសុក្រឹតពីលក្ខណៈនៃហានិភ័យបរិស្ថាន ប្រសើរជាងការគិតដោយពុំមានព័ត៌មានពីហានិភ័យ។ វាបង្ហាញពីសារៈសំខាន់នៃការកំណត់អត្តសញ្ញាណ ការរៀបរាប់ និងលទ្ធភាពកំណត់ជាបរិមាណផលប៉ះពាល់ដែលអាចនឹងកើតឡើងរបស់សំណើបញ្ញត្តិកម្ម។

វិធានទូទៅ ការប៉ាន់ស្មានការវាយតម្លៃរបស់បុគ្គលលើទំនិញ និងសេវាដែលចេញមកពីការសង្កេតឥរិយាបថរបស់ពួកគេចំពោះនិន្នាការទីផ្សារដែលអាចជឿជាក់បានជាងការធ្វើអង្កេតដោយកម្រង់សំណួរ (Boardman et al. 2010) ។ ការសង្កេតលើការសម្រេចចិត្តទិញបានបង្ហាញ *ដោយផ្ទាល់* ពីការពេញចិត្ត។

អ្នកឆ្លើយនឹងសំណួរអង្កេត អាចមានការលើកទឹកចិត្តតិចតួចក្នុងការទទួលយកសំណួរដោយយកចិត្តទុកដាក់វិនិយោគក្នុងការទទួលបានព័ត៌មានចាំបាច់សម្រាប់ការឆ្លើយតបដោយភាពសុក្រឹត ឬក៏មានកាជឿជាក់បាន។ ពួកគេត្រូវទទួលបន្ទុកចំណាយតិចតួចចំពោះចម្លើយមិនពិតប្រាកដ ហើយអាចមានការបំផ្លើស។

## *ការកំណត់ការវាយតម្លៃលើផលប៉ះពាល់ពីប្រភពទី២*

វិធីសាស្ត្រដែលបានពិភាក្សានៅខាងលើ ផ្ដល់នូវសំណុំនៃឧបករណ៍សម្រាប់ការការវាយតម្លៃជាក់ស្តែងលើផលប៉ះពាល់ ក៏ប៉ុន្តែប្រហែលជាមានការលំបាកក្នុងការអនុវត្ត។ នៅពេលអ្នកមិនមានធនធានឬជំនាញក្នុងការសិក្សាដំបូង អ្នកអាច "បញ្ចូល" តម្លៃពីការសិក្សាមុនៗ។ ដំណើរការនេះគេហៅថា "ផ្ទេរផលចំណេញ" ត្រូវបានគេប្រើប្រាស់ដើម្បីប៉ាន់ស្មានតម្លៃ ដូចជាតម្លៃនៃស្ថិតិជីវិតឬឆ្នាំជីវិត តម្លៃនៃការសន្សំពេលវេលាធ្វើដំណើរ និងបន្ទុកចំណាយនៃការរំខានដោយសំឡេង និងការបំពុលខ្យល់។

ខណៈព័ត៌មានពីប្រភពទី២ដែលមានស្រាប់ផ្សេងទៀតអាចផ្ដល់បានរហ័សនូវវិធីសាស្ត្រមានតម្លៃទាប ដើម្បីវាយតម្លៃជារូបិយវត្ថុ ដែលអ្នកត្រូវការប្រើប្រាស់វាដោយប្រុងប្រយ័ត្ន ហើយក៏កុំប្រើប្រាស់វាដោយគ្មានហេតុផលច្បាស់លាស់។ វាតម្រូវឲ្យមានការវិនិច្ឆ័យ ដើម្បីកំណត់ថាតើលទ្ធផលបានមកពីការសិក្សាមុនៗសមរម្យសម្រាប់ការប្រើប្រាស់នៅក្នុងCBAណា

មួយ។ ការប៉ាន់ស្មានបានមកពីប្រភពទី២ដែលមានស្រាប់ផ្សេងទៀត អាចធ្វើការកែសម្រួលអាស្រ័យទៅលើភាពជាក់លាក់នៃការអនុវត្តណាមួយ។

សុក្រឹតភាពនិងគុណភាពនៃការសិក្សាដំបូង គួរត្រូវពិនិត្យដោយប្រុងប្រយ័ត្ន។ នៅពេលការសិក្សាដោយប្រើប្រាស់បច្ចេកទេសមានភាពទន់ខ្សោយ អ្នកគួរពិភាក្សាចំណុចលម្អៀងណាមួយ ឬភាពមិនប្រាកដប្រជាដែលអាចកើតឡើងជាលទ្ធផល។ ច្បាស់ណាស់ ប្រសិនបើការសិក្សាមួយដែលមានចំណុចខ្សោយខ្លាំង នោះមិនគួរត្រូវបានប្រើប្រាស់ទេ។ម្យ៉ាងទៀតព័ត៌មានបានមកពីប្រភពទី២ដែលមានស្រាប់ផ្សេងទៀតគឺមានភាពខ្លាំងបំផុត នៅពេលប្រភពមួយចំនួនអាចត្រូវបានប្រើប្រាស់ ដើម្បីជាជំនួយបន្ថែមដល់ការសន្មត ឬការប៉ាន់ស្មាន។

### *ដំណោះស្រាយចំពោះបន្ទុកចំណាយ និងផលចំណេញដែលមិនអាចកំណត់តម្លៃជាដុល្លារ*

បន្ទុកចំណាយ និងផលចំណេញខ្លះមិនទទួលបាននូវការកំណត់តម្លៃជាដុល្លារ។ ទោះយ៉ាងណាក្តីCBAគួរបានបញ្ចូលព័ត៌មានពាក់ព័ន្ធទាំងអស់ ដែលអាចប៉ះពាល់ដល់ការសម្រេចចិត្តក្នុងករណីនេះ។ វាគួរតែគិតឲ្យបានច្បាស់ពីបន្ទុកចំណាយ និងផលចំណេញដែលមិនអាចកំណត់តម្លៃបាន។ អ្នកគួររៀបចំរបាយការណ៍ពីបន្ទុកចំណាយ និងផលចំណេញប៉ានស្មានតាមប្រភេទ៣ ៖

• កំណត់ជាទឹកប្រាក់

• កំណត់ជាបរិមាណប៉ុន្តែមិនមែនជាទឹកប្រាក់

• បែបគុណភាព ប៉ុន្តែមិនមែនបរិមាណ ឬកំណត់ទឹកប្រាក់

បញ្ហាប្រឈម គឺការពិចារណាលើផលប៉ះពាល់ដែលមិនអាចគិតចេញជាទឹកប្រាក់បាន ដោយមានភាពគ្រប់គ្រាន់។ ឧទាហរណ៍ ប្រសិនបើសំណើបញ្ញត្តិកម្មមួយមានការគាំទ្រ ហើយ បើទោះបីជាផលចំណេញតិចជាងច្រើនបន្ទុកចំណាយកំណត់ជាទឹកប្រាក់បានក៏ដោយ ក៏របាយការណ៍RISគួរពន្យល់ឲ្យបានច្បាស់លាស់នូវមូលហេតុនៃផលចំណេញនោះដែលមិនអាចកំណត់ជាទឹកប្រាក់បានហើយអាចនៅមានអំណោយផលទៀត និងភាពមិនប្រាកដប្រជានៃទំហំនៃផលចំណេញផង។

CBA អាចលើកទឹកចិត្តដល់អ្នកធ្វើសេចក្តីសម្រេចសម្រាប់បង្ហាញពីការលំបាកក្នុងការកំណត់បាននូវផលចំណេញមិនកំណត់ជាទឹកប្រាក់បាន។ ឧទាហរណ៍ សំណើបញ្ញត្តិកម្មមួយ ដែលមានបន្ទុកចំណាយគិតជាទឹកប្រាក់អាចលើសការកំណត់ជាទឹកប្រាក់នូវផលចំណេញរហូតដល់១៦លានដុល្លារ ដែលស្មើនឹងបន្ទុកចំណាយសុទ្ធ១ដុល្លារសម្រាប់ប្រជាជនកម្ពុជាម្នាក់ សម្រាប់រយៈពេលសុពលភាពនៃលិខិតបទដ្ឋានគតិយុត្ត។ តើផលចំណេញមិនអាចគិតជាទឹកប្រាក់បាន មានតម្លៃច្រើនជាងបន្ទុកចំណាយដែលអាចគិតជាទឹក

ប្រាក់បានឬទេ? វាគួរគិតពិចារណាឲ្យបានសមហេតុផល ដើម្បីសន្មតថា ប្រជាជនឲ្យតម្លៃសំណើបញ្ញត្តិកម្មដែលផ្ដល់ផលចំណេញមិនអាចគិតជាទឹកប្រាក់បានជាង១ដុល្លារក្នុងមួយនាក់ៗ។ ក៏ប៉ុន្តែប្រសិនបើបន្ទុកចំណាយអាចនិយាយបានថា ១00ដុល្លារក្នុងមួយនាក់ នោះមិនអាចទទួលយកបានទេ ក្នុងការសន្មតថាមានឆន្ទៈខ្ពស់ក្នុងការបង់ថ្លៃសម្រាប់លិខិតបទដ្ឋានគតិយុត្តដែលផ្ដល់ផលចំណេញដែលមិនអាចគិតជាទឹកប្រាក់បាន ទៅតាមផលចំណេញនោះ។

ប្រសិនបើការកំណត់ជាបរិមាណមិនអាចទៅរួច យ៉ាងហោចណាស់ការវិភាគរបស់អ្នកគួរតែរៀបរាប់តាមបែបគុណភាព និងវាយតម្លៃចំណុចខ្លាំង និងចំណុចខ្សោយដោយលើកឡើងនូវទឡ្ហីករណ៍ដែលមានប្រយោជន៍ពាក់ព័ន្ធនឹងបញ្ហានោះ។ គួរបញ្ចូលទិន្នន័យពាក់ព័ន្ធ ដើម្បីគាំទ្រការវិភាគតាមបែបគុណភាពប្រសិនបើមានលទ្ធភាព។ ឧទាហរណ៍ ព័ត៌មានអំពីចំនួនប្រជាជនរងផលប៉ះពាល់ដោយសំណើបញ្ញត្តិកម្ម ឬតម្លៃបន្ថែមរបស់ឧស្សាហកម្មរងផលប៉ះពាល់ អាចមានប្រយោជន៍សម្រាប់អ្នកធ្វើសេចក្ដីសម្រេចចុងក្រោយ។

## *ការវិភាគប្រសិទ្ធភាពចំណាយ*

ការវិភាគប្រសិទ្ធភាពចំណាយ គឺជាជម្រើសដែលគេប្រើប្រាស់យ៉ាងទូលំទូលាយជំនួសឲ្យCBA ក្នុងកាលៈទេសៈខ្លះ ដែលផលប៉ះពាល់សំខាន់បំផុតមិនអាចកំណត់ជាទឹក

ប្រាក់បាន។ ប្រៀបធៀបជម្រើសផ្សេងៗ តាមរយៈអនុបាតនៃបន្ទុកចំណាយនិងតួលេខតែមួយ ប៉ុន្តែមិនបានកំណត់ជាទឹកប្រាក់ទេ ការវាស់វែងប្រសិទ្ធភាពដូចជាការសង្គ្រោះជីវិត។ វាមានហេតុផលក្នុងការប្រើប្រាស់ការវិភាគប្រសិទ្ធភាពចំណាយប្រសិនបើការវាស់វែងប្រសិទ្ធភាពអាចគ្រប់ដណ្តប់ផលចំណេញនៃគោលនយោបាយភាគច្រើនបំផុត។

ការវិភាគអត្ថប្រយោជន៍បន្ទុកចំណាយ គឺជាទម្រង់មួយនៃការវិភាគប្រសិទ្ធភាពចំណាយ ដែលប្រើប្រាស់ការវាស់វែងប្រសិទ្ធភាពស្មុគស្មាញច្រើន ដោយឆ្លុះបញ្ចាំងទាំងបរិមាណនិងគុណភាព។ ជាទូទៅ វាត្រូវបានគេប្រើប្រាស់ក្នុងវិស័យថែទាំសុខភាព។ ឧទាហរណ៍ ការវាស់វែងផលចំណេញអាចជាការកែសម្រួលគុណភាពឆ្នាំជីវិត ដែលរួមផ្សំចំនួនឆ្នាំជីវិតបន្ថែមនិងគុណភាពជីវិត ក្នុងអំឡុងពេលឆ្នាំទាំងនោះ (ជាទូទៅ គេវាស់តាមកម្រិតនៃតម្លៃមួយ ដោយកំណត់សម្រាប់មនុស្សដែលមានសុខភាពល្អបំផុត និងសូន្យសម្រាប់មនុស្សដែលស្លាប់)។ ក្នុងការវិភាគអត្ថប្រយោជន៍បន្ទុកចំណាយ បន្ទុកចំណាយបន្ថែមនៃជម្រើសមួយចំនួនត្រូវបានធ្វើការប្រៀបធៀបទៅនឹងការផ្លាស់ប្តូរសុខភាព ដែលបានវាស់វែងនៅក្នុងការកែសម្រួលគុណភាពឆ្នាំជីវិត ដែលពួកគេបានបង្កើតឡើង។ ការវាស់វែងប្រសិទ្ធភាពចំណាយបែបនេះ ក៏ត្រូវបានប្រើប្រាស់ សម្រាប់ការកែសម្រួលឆ្នាំជីវិតអ្នកភាពពិការដែរ។

## ការពិចារណាលើសមធម៌

ការវិភាគ CBA បានបន្ថែមបន្ទុកចំណាយនិងផលចំណេញដល់បុគ្គលទាំងអស់ដោយមិនគិតពីសមធម៌នៃការបែងចែកបន្ទុកចំណាយនិងផលចំណេញទាំងនោះឡើយ។ CBA បង្ហាញអំពីការគិតប្រាក់ចំណេញមួយដុល្លារចំពោះមនុស្សម្នាក់ ដោយមិនគិតថាមនុស្សម្នាក់ទៀតខាតប្រាក់មួយដុល្លារនោះទេ។ ការវិភាគនេះ សន្មតថាប្រាក់មួយដុល្លារមានតម្លៃដូចគ្នាសម្រាប់មនុស្សគ្រប់ៗរូប។ ឬក៏អាចនិយាយបានថាCBAត្រូវបានគេប្រើប្រាស់ ដើម្បីបង្ហាញថាសំណើមួយផ្តល់ផលចំណេញសុទ្ធគិតជាដុល្លារចំពោះសង្គមទាំងមូល ជាជាងគិតថាអ្នកណាទទួលផលចំណេញ ឬអ្នកណាខាតបង់ ។

ការសន្មត "ដុល្លារ គឺមួយដុល្លារ" បានចែកញែកប្រសិទ្ធភាពនៃគោលនយោបាយមួយ ឬឥទ្ធិពលនៃការបែងចែកធនធានចេញពីសមធម៌ឬការបែងចែកឥទ្ធិពល។ ការបែងចែកនេះជាវិធីសាស្រ្តដ៏មានអត្ថប្រយោជន៍ ដោយសារតែមិនមានការយល់ស្របណាមួយអំពីបន្ទុកដែលត្រូវភ្ជាប់នឹងឥទ្ធិពលនៃសមធម៌។ ដែលប្រសើរបំផុត វាអាស្រ័យទៅលើអ្នកសម្រេចចិត្តក្នុងការសម្រេចអំពីការថ្លឹងថ្លែងរវាងសមធម៌និងប្រសិទ្ធផល។ CBA គ្រាន់តែអាចជួយផ្តល់ជាព័ត៌មានដល់ការសម្រេចចិត្តប៉ុណ្ណោះ។

វិធីដែលបន្ទុកចំណាយនិងផលចំណេញត្រូវបានបែងចែកក្នុងចំណោមក្រុមផ្សេងៗ និងក្នុងរយៈពេលណាមួយក៏អាចមានសារៈសំខាន់សម្រាប់អ្នកសម្រេចចិត្តផងដែរ។ ទោះបី CBA មិនអាចដោះស្រាយបញ្ហាសមធម៌ តែCBA អាចទាញចំណាប់អារម្មណ៍មកលើបញ្ហានេះដោយបង្ហាញទំហំនៃផលប៉ះពាល់នៃវិធានការណ៍ដែលបានស្នើទៅលើក្រុមផ្សេងៗ។ ប្រសិនបើមានព័ត៌មានដែលអាចរកបាន CBAអាចសំគាល់អ្នកឈ្នះនិងអ្នកចាញ់និងទំហំនៃផលចំណេញនិងការខាតបង់របស់ពួកគេ។ ដូច្នេះវាស្ថិតទៅលើអ្នកសម្រេចចិត្តក្នុងការសម្រេចថាតើផលប៉ះពាល់នៃការបែងចែក ឬបញ្ហាសមធម៌មានសារៈសំខាន់ឬមិនសំខាន់ហើយត្រូវការដោះស្រាយតែប៉ុណ្ណោះ។

CBA បង្ហាញឲ្យឃើញច្បាស់ពីការថ្លឹងថ្លែងនៅពេលដែលប្រៀបធៀបជាមួយនឹងជម្រើសសំណើផ្សេងៗ ដូចជាតើប្រាក់ចំណេញប៉ុន្មាននឹងត្រូវលះបង់ដើម្បីសម្រេចគោលបំណងផ្សេងទៀត។ ឧទាហរណ៍ អ្នកសម្រេចចិត្តប្រហែលជាត្រូវសម្រេចចិត្តថានឹងត្រូវបដិសេធជម្រើសមួយដែលមាន NPV ធំជាងគេ ប្រសិនបើវាមានផលប៉ះពាល់អវិជ្ជមានគួរឲ្យកត់សំគាល់ដល់សមធម៌។ ហេតុផលតែត្រូវបង្ហាញឲ្យបានឃើញច្បាស់។

### *ការពិចារណាសម្រាប់អ្នកជំនាន់ក្រោយ*

បញ្ហានឹងកើតឡើងនៅពេលដែលផលប៉ះពាល់នៃបញ្ញត្តិកម្មនៅបន្តរហូតដល់អ្នកជំនាន់ក្រោយ (ឧទាហរណ៍ នៅពេលបន្ទុកចំណាយត្រូវបានរ៉ាប់រងដោយអ្នកជំនាន់បច្ចុប្បន្ន ប៉ុន្តែផលចំណេញបានចែករំលែក ឬបានទទួលដល់អ្នកជំនាន់ក្រោយ)។ អ្នកខ្លះបានលើកឡើងថា អត្រាបញ្ចុះតម្លៃទាប គួរត្រូវប្រើប្រាស់សម្រាប់ការបញ្ចុះតម្លៃដែលមានលក្ខណៈឆ្លងជំនាន់។ ក៏ប៉ុន្តែមិនមានការយល់ស្របណាមួយអំពីរបៀបប៉ាន់តម្លៃផលប៉ះពាល់ទៅអ្នកជំនាន់ក្រោយនោះទេ។

មានការស្នើថាឥទ្ធិពលទៅលើអ្នកជំនាន់ក្រោយគួរតែត្រូវពិចារណាឲ្យបានច្បាស់លាស់ ជាជាងការប្រើប្រាស់អត្រាបញ្ចុះតម្លៃទាបទៅតាមអំពើចិត្ត។ វិធីមួយដើម្បីសម្រេចបានកត្តានេះ គឺការបន្ថែមលើCBA ជាមួយនឹងការពិភាក្សាមួយអំពីរបៀបដែលជំនាន់ក្រោយនឹងត្រូវរងឥទ្ធិពលពីសំណើបញ្ញត្តិកម្ម។

## កំហុសធម្មតាក្នុងការវិភាគបន្ទុកចំណាយនិងផល ចំណេញ

កំហុសធម្មតាមួយចំនួនដែលកើតឡើងជាពិសេសក្នុងការវិភាគសំណើបញ្ញត្តិកម្មមានដូចតទៅ៖

### *ភាពព្រងើយកន្តើយឬការបន្ទាបកម្រិត បន្ទុកចំណាយ និងផលចំណេញផ្នែកសង្គមដែលមិនមានលក្ខណៈហិរញ្ញវត្ថុ*

សំណើបញ្ញត្តិកម្មអាចមាន ភាពងាយស្រួល និងភាពត្រឹមត្រូវខុសប្លែកគ្នាយ៉ាងខ្លាំងនៅពេលបន្ទុកចំណាយនិងផលចំណេញដែលទំនងជាអាចកំណត់បរិមាណបាន។ ទោះបីជា CBA សង្កត់ធ្ងន់ទៅលើការប៉ាន់តម្លៃបន្ទុកចំណាយនិងផលចំណេញគិតជាទឹកប្រាក់ក៏ដោយ ក៏វាមានសារៈសំខាន់ដែលថាដំណើរការរៀបចំរបាយការណ៍វាយតម្លៃពេញលេញ (RIS) មិនមានភាពលំអៀងទៅខាងសំណើដែលមានផលប៉ះពាល់ងាយប៉ាន់តម្លៃជាងនោះទេ។ អ្នកត្រូវយកចិត្តទុកដាក់ធានាថាផលប៉ះពាល់គិតជាទឹកប្រាក់មិនមានទម្ងន់លើសលុប ឬគ្របដណ្តប់ទៅលើកត្តាសំខាន់ៗផ្សេងទៀតនៅក្នុងការសម្រេចចិត្ត។

### *ផលចំណេញដែលរាប់ទ្វេរដង*

ប្រសិនបើបន្ទុកចំណាយនិងផលចំណេញនៃការផ្លាស់ប្តូរបញ្ញត្តិកម្មមួយត្រូវបានប៉ាន់ប្រមាណចេញពីផលប៉ះពាល់

នៅក្នុងទីផ្សារមួយ សូមកុំរាប់បញ្ចូលបន្ទុកចំណាយនិងផលចំណេញទាំងនេះម្តងទៀត ថាជាលទ្ធផលនៃការផ្លាស់ប្តូរនៅក្នុងទីផ្សារដទៃ។ ឧទាហរណ៍ថា ប្រសិនបើការផ្លាស់ប្តូរទៅលើបទប្បញ្ញត្តិវិស័យដឹកជញ្ជូន ផ្តល់ផលជាការសន្សំសំចៃពេលវេលាធ្វើដំណើរដល់ក្រុមម្ចាស់ផ្ទះណាមួយនោះ វាមិនត្រឹមត្រូវនោះទេដែលបន្ថែមលទ្ធផលនៃការឡើងថ្លៃតម្លៃផ្ទះរបស់ពួកគេនោះទេ (ដែលគ្រាន់តែផលចំណេញផ្នែកមូលធនស្រដៀងគ្នាដែលបានរាប់បញ្ចូលរួចហើយតែប៉ុណ្ណោះ) ទៅលើផលចំណេញពេលវេលាធ្វើដំណើរ កើតឡើងដោយសារការផ្លាស់ប្តូរបញ្ញត្តិកម្ម។

ករណីទូទៅជាងនេះទៅទៀត ផលប៉ះពាល់នឹងតែងតែបង្ហាញចេញនៅក្នុងរបៀបពីរយ៉ាង៖ ផលប៉ះពាល់ជាក់ស្តែង (ឧទាហរណ៍ ផលចំណេញពេលវេលា ឬកំណើនផលិតភាពការងារ) និងផលប៉ះពាល់ធម្មតានៅពេលដែលផលប៉ះពាល់ជាក់ស្តែងត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទីផ្សារ។ ករណីណាមួយក៏អាចត្រូវបានប្រើប្រាស់ ដើម្បីដាក់តួលេខជាដុល្លារចំពោះផលប៉ះពាល់ទាំងនោះដែរ ប៉ុន្តែគួរយកចិត្តទុកដាក់ថា ក្នុងការវិភាគមិនត្រូវរាប់បញ្ចូលព្រមគ្នានូវផលប៉ះពាល់ទាំងពីរនេះទេ។

*"មុន/ឬក្រោយ" ប្រសើរជាង "មាន/ឬមិនមាន"*

បន្ទុកចំណាយនិងផលចំណេញនៃសំណើបញ្ញត្តិកម្មមួយ វាពាក់ព័ន្ធយ៉ាងពិតប្រាកដទៅនឹងការផ្លាស់ប្តូរនានា បើប្រៀបធៀបទៅនឹងអ្វីដែលនឹងកើតឡើងនៅពេលគ្មានបញ្ញត្តិកម្ម។ ហេតុដូច្នេះ ការប្រៀបធៀបរវាងពិភពលោកដែលគ្មានការផ្លាស់ប្តូរជាមួយនឹងពិភពលោកដែលមានការផ្លាស់ប្តូរ ពិតជាមានភាពចាំបាច់ខ្លាំងណាស់។ វាមិនមានភាពសមស្របនោះទេ ដោយគ្រាន់តែគណនាបន្ទុកចំណាយនិងផលចំណេញបន្ថែមដោយប្រៀបធៀបទៅនឹងស្ថានភាពដើម លុះត្រាគ្មានការផ្លាស់ប្តូរបន្ថែមកើតឡើងនៅពេលអវត្តមាននៃសំណើ។

បញ្ហានេះកើតឡើងជាពិសេសនៅពេលដែលមានការវាយតម្លៃទៅលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដែលជាផ្នែកមួយនៃគោលនយោបាយដែលមានបំណងដូចគ្នា (ឧទាហរណ៍ មានគោលនយោបាយមួយចំនួនដែលមានបំណងកាត់បន្ថយការប្រើប្រាស់អគ្គិសនីនៅក្នុងអគារ និងបញ្ញត្តិកម្មមួយចំនួនដែលមានបំណងកាត់បន្ថយការជក់បារី)។ ក្នុងករណីទាំងនេះ វាមានសារៈសំខាន់ណាស់ចំពោះការវិភាគផលប៉ះពាល់បន្ថែមទៅលើបញ្ញត្តិកម្មដែលកំពុងត្រូវបានពិចារណា ដោយទទួលស្គាល់ថា ទោះបីគ្មានវិធានការណ៍ណាមួយត្រូវបានធ្វើឡើងក៏ដោយ ក៏វិធានការណ៍ផ្សេងទៀតរបស់រដ្ឋាភិបាលអាចនឹងនឹងប្រព្រឹត្តឡើង ដើម្បីទទួលបានលទ្ធផលដែលចង់បាន។ ហេតុដូច្នេះ ជម្រើសករណីស្ថានភាពដើម

"ភាពគ្មានបញ្ញត្តិកម្ម" គួរដាក់បញ្ចូលផលប៉ះពាល់នៃការធ្វើអន្តរាគមន៍បំពេញបន្ថែមទាំងនេះ។ បន្ថែមលើនេះទៅទៀត អ្នកគួរតែពិចារណាថាតើ សហគមន៍នឹងផ្លាស់ប្តូរអាកប្បកិរិយារបស់ខ្លួនដែរឬទេ ក្នុងករណីគ្មានវិធានការរបស់រដ្ឋាភិបាល។

## *ការប្រើប្រាស់អត្រាការប្រាក់គ្មានហានិភ័យ ដើម្បីបញ្ចុះតម្លៃផលចំណេញសុទ្ធ ដែលមានហានិភ័យទីផ្សារ*

អត្រាការប្រាក់គ្មានហានិភ័យ គួរត្រូវបានប្រើក្នុងលក្ខ-ខណ្ឌដើម្បីបញ្ចុះតម្លៃផលចំណេញសុទ្ធដែលមិនមានជាប់ពាក់ព័ន្ធនឹងផលចំណេញខាងទីផ្សារ។ ការប្រើប្រាស់ "អត្រាបញ្ចុះតម្លៃសង្គម"ទាប គឺជារឿងធម្មតានៅក្នុងមេរៀន CBA ហើយជាទូទៅមានលក្ខណៈសមស្របតាមរយៈអំណះអំណាងខាងក្រោម៖

- រដ្ឋាភិបាលអាចខ្ចីតាមរយៈការប្រាក់មូលបត្រ សញ្ញា-ប័ណ្ណបំណុល(Bond) ដែលជាធម្មតាមានអត្រាការប្រាក់ទាបជាងទីផ្សារ ហេតុដូច្នេះអត្រាផលចំណេញផ្តល់ដោយរដ្ឋាភិបាលគឺមានកម្រិតទាបជាងអត្រាផលចំណេញផ្តល់ដោយវិស័យឯកជន។
- រដ្ឋាភិបាលមានភាគហ៊ុននៃ"វិនិយោគ"ចម្រុះ ហេតុដូច្នេះរដ្ឋាភិបាលមិនប្រឈមនឹងហានិភ័យទីផ្សារនោះឡើយ។

- សង្គមមិនគួរបន្ទាបតម្លៃសុខុមាលភាពរបស់អ្នកជំនាន់ក្រោយនោះឡើយ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏អំណះអំណាងទាំងនេះមិនសុទ្ធតែជាហេតុផលសម្រាប់កិច្ចអន្តរាគមន៍ដោយចេញបទបញ្ញត្តិនោះទេ។ ទោះតាមពិត រដ្ឋាភិបាលអាចកៀងគរថវិកាក្នុងកម្រិតអត្រាការប្រាក់ទាបតាមរយៈមូលបត្រសញ្ញាប័ណ្ណក៏ដោយ វាក៏ជាថ្លៃឱកាសនៃថវិកាទាំងនោះ (ដែលថវិកាទាំងនោះអាចយកទៅប្រើប្រាសលើជម្រើសផ្សេងៗទៀតបាន) ដែលវាសំខាន់ណាស់ ជាជាងការចំណាយលើការប្រាក់ក្នុងការពិចារណាទៅលើផលប៉ះពាល់ផ្នែកសង្គម។ បន្ថែមលើនេះទៅទៀត រដ្ឋាភិបាលជាទូទៅមិនមានជំនាញធ្វើពិពិធកម្មវិនិយោគក្នុងវិស័យចម្រុះនិងមិនមានជំនាញខាងធ្វើការប្រើប្រាស់ទ្រព្យសកម្មដើម្បីវិនិយោគ មិនដូចបុគ្គលនិងអ្នកវិនិយោគម្នាក់ៗ។ ជាចុងបញ្ចប់អ្នកមិនគួរគណនាសម្រាប់សុខុមាលភាពរបស់អ្នកជំនាន់ក្រោយ ដោយការកែសម្រួលអត្រាបញ្ចុះតម្លៃនោះឡើយ។ ដើម្បីធ្វើបែបនេះបាន គឺត្រូវការកំណត់ទំហំតម្លៃប្រៀបធៀបនៃសុខុមាលភាពរបស់មនុស្សតាមជំនាន់ផ្សេងៗគ្នា ហើយក្នុងការអនុវត្តបែបនេះក៏មិនអាចទទួលយកបានឡើយ។ ផ្ទុយមកវិញ អ្នកគួរតែពិចារណាទៅលើផលប៉ះពាល់របស់សំណើមួយទៅលើអ្នកជំនាន់ក្រោយឲ្យបានច្បាស់លាស់។

# ឯកសារយោង និងព័ត៌មានបន្ថែម

Boardman, E.A., Greenberg, D.H., Vining, A.R. and Weimer, D.L. 2010, *Cost–benefit analysis: concepts and practice*, 4th edition, Pearson Prentice Hall, New Jersey.

Commonwealth of Australia 2006, *Handbook of cost–benefit analysis*, Financial Management Reference Material No. 6, January, Canberra.

Harrison, M. 2010, *Valuing the future: the social discount rate in cost–benefit analysis*, Visiting Researcher Paper, Productivity Commission, Canberra.

Baker, R. and Ruting, B. 2014, *Environmental policy analysis: a guide to non-market valuation*, Productivity Commission, Canberra, http://www.pc.gov.au/research/staff-working/non-market-valuation.

NSW Treasury (New South Wales Treasury) 2007, *Guidelines for economic appraisal*, Office of Financial Management, Treasury Policy and Guidelines Paper 07–5.

OECD (Organisation for Economic Co-operation and Development) 2006, *Cost–benefit analysis and the environment: recent developments*.

USOMB (United States Office of Management and Budget) 2003, *Regulatory Analysis*, Circular A-4, September.

# ឧបសម្ព័ន្ធ – ឧទាហរណ៍ CBA

នាពេលថ្មីៗនេះមានករណីក្មេងស្លាប់ និងជិតស្លាប់ដោយសារការលង់ទឹកនៅប្រទេសអូស្ត្រាលី។ ក្រសួងសុខាភិបាលកត់សម្គាល់ថាមិនមានឧប្បត្តិហេតុនៅក្នុងអាងហែលទឹកដែលហ៊ុំព័ទ្ធដោយរបងទេ ហើយរដ្ឋាភិបាលអូស្ត្រាលីកំពុងពិចារណាធ្វើឲ្យវាក្លាយជាកាតព្វកិច្ចចាប់តាំងពីឆ្នាំ២០១៧ ដើម្បីសាងសង់របងជុំវិញអាងហែលទឹកទើបសាងសង់ថ្មីៗ។ ដើម្បីធានាបាននូវការអនុលោមតាមច្បាប់ថ្មី រដ្ឋាភិបាលនឹងបញ្ជូនអ្នកត្រួតពិនិត្យជារៀងរាល់ឆ្នាំដើម្បីពិនិត្យមើលថាតើអាងទឹកដែលបានសាងសង់ពីឆ្នាំ ២០១៧ មានរបងបានសាងសង់ដែរឬទេ។

រដ្ឋាភិបាលបានស្នើសុំឲ្យអ្នកធ្វើការវិភាគបន្ទុកចំណាយ និងផលចំណេញ ថាតើគោលនយោបាយនេះ គឺជាគំនិតល្អឬទេ។ តើអ្វីដែលអ្នកនឹងផ្តល់អនុសាសន៍ដល់រដ្ឋាភិបាល?

នេះគឺជាព័ត៌មានដែលអ្នកនឹងត្រូវការដើម្បីវិភាគ៖

***ចំនួនអាងហែលទឹក***

- នៅឆ្នាំ ២០១៦ មានអាងហែលទឹកចំនួន ៥00,000 ហើយ ២0% បានហ៊ុមព័ទ្ធរួចហើយ។ ចំនួនអាងហែលទឹកកើនឡើង ៣% ក្នុងមួយឆ្នាំ។

***ការចំណាយ***

• តំលៃ ២,៥០០ ដុល្លារដើម្បីដំឡើងរបងថ្មីនិងជាមធ្យម ២៥ ដុល្លារក្នុងមួយឆ្នាំដើម្បីថែរក្សារបង។

• តំលៃ ៤០ ដុល្លារដើម្បីត្រួតពិនិត្យអាងនីមួយៗហើយ អាងហែលទឹក ២៥% ត្រូវបានសាងសង់ចាប់ពីឆ្នាំ ២០១៧ ត្រូវបានត្រួតពិនិត្យជារៀងរាល់ឆ្នាំ។

***ចំនួននៃការលង់ទឹកស្លាប់ និង ការលង់ទឹកជិតស្លាប់***

•នៅឆ្នាំ ២០១៦ មានមនុស្ស ២០ នាក់បានលង់ទឹកស្លាប់ និង៥០នាក់បានលង់ទឹកជិតស្លាប់ នៅក្នុងអាងទឹកដែលគ្មានរបង។ មិនមានឧប្បត្តិហេតុណាមួយនៅក្នុងអាងទឹកដែលមានរបងហ៊ុមព័ទ្ធនោះទេ។

***តម្លៃនៃការលង់ទឹកស្លាប់***

•តម្លៃជីវិតម្នាក់ ត្រូវបានប៉ាន់ប្រមាណថាមានតម្លៃ ៣ លានដុល្លារ។

•ថ្លៃសុខភាពជាក់ស្តែងដែលជាប់ទាក់ទងជាមួយការលង់ទឹកជិតស្លាប់មានតម្លៃ ៥,០០០ ដុល្លារក្នុងមួយករណី ហើយការចំណាយសុខភាពរយៈពេលវែងគឺ ៥០០,០០០ ដុល្លារក្នុងមួយករណី។

•គុណភាពជីវិតដែលកំពុងបន្តសម្រាប់កុមារដែលលង់ទឹកជិតស្លាប់គឺ ០.៨ នៃ QALY ។

***អត្រាបញ្ចុះតម្លៃ***

•អត្រាបញ្ចុះតម្លៃ ៧%

***រយៈពេលនៃការវិភាគ***

•១០ឆ្នាំ

# តារាង ក.១: ការសន្មត និង ទិន្នន័យ

| | | | | |
|---|---|---|---|---|
| | | ចំនួនអាងទឹក | ៥០០០០០ | |
| | | កំណើន១ឆ្នាំ | ៣% | |
| | | ចំនួនអាងទឹកមានរបង ស្រាប់ | ២០% | |
| បន្ទុកចំណាយ | A | ថ្លៃតម្លើងរបង | $ ២៥០០ | ក្នុង១អាង ទឹក |
| | B | ថ្លៃថែទាំរបង | $ ២៥ | ១អាង ១ឆ្នាំ |
| | C | ថ្លៃចុះអធិការកិច្ចរបង | $ ៤០ | ក្នុង១អាង |
| | D | អត្រានៃការចុះអធិការកិច្ច | ២៥% | ក្នុង១ឆ្នាំ |
| ផលចំណេញ | | ក្មេងលង់ទឹកស្លាប់ | ២០ | ក្នុងអាង ដែលមិន មានរបង |
| | E | *- អត្រាស្លាប់* | *0,0000៥00* | *ក្នុងអាង ដែលមិន មានរបង១* |
| | | ក្មេងលង់ទឹកជិតស្លាប់ | ៥០ | ក្នុងអាងមិន មានរបង |
| | F | *- អត្រាជិតស្លាប់* | *0,000១២៥០* | *ក្នុងអាង ដែលមិន មានរបង១* |
| | G | ថ្លៃជីវិតម្នាក់ | *$៣,000,000* | |
| | H | ថ្លៃថែទាំស្រួចស្រាវ | $៥.០០០ | ក្នុង១ករណី |
| | I | ថ្លៃសុខភាពបន្ត | $៥០០,០០០ | ក្នុង១ករណី |
| | J | QALY | ០.៨ | |
| | K | *- បាត់បង់សុខភាព* | *០.២* | |
| | | អត្រាបញ្ចុះតម្លៃ | ៧% | |

**តារាង ក.២: ការគណនាតម្លៃបច្ចុប្បន្នសុទ្ធ (NPV)**

| | | | | ឆ្នាំ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 | 2024 | 2025 | 2026 |
| | **ករណីមូលដ្ឋាន (មិនមានបញ្ញត្តិកម្ម)** | | | | | | | | | | | | | |
| | ចំនួនអាងហែលទឹក | | 500,000 | 515000 | 530450 | 546363.5 | 562754.405 | 579637.0372 | 597026.1483 | 614936.9327 | 633385.0407 | 652386.5919 | 671958.1897 |
| L | - ចំនួនអាងហែលទឹកដែលមានរបង | | 100,000 | 103000 | 106090 | 109272.7 | 112550.881 | 115927.4074 | 119405.2297 | 122987.3865 | 126677.0081 | 130477.3184 | 134391.6379 |
| M | - ចំនួនអាងហែលទឹកដែលមិនមានរបង | | 400,000 | 412000 | 424360 | 437090.8 | 450203.524 | 463709.6297 | 477620.9186 | 491949.5462 | 506708.0326 | 521909.2735 | 537566.5517 |
| | - អាងហែលទឹកដែលបានសាងសង់២០១៧ | | | 15,000 | 30,450 | 46,364 | 62,754 | 79,637 | 97,026 | 114,937 | 133,385 | 152,387 | 171,958 |
| N | ចំនួនក្មេងលង់ទឹកស្លាប់ | (L*E) | 20 | 20.60 | 21.22 | 21.85 | 22.51 | 23.19 | 23.88 | 24.60 | 25.34 | 26.10 | 26.88 |
| O | ចំនួនក្មេងលង់ទឹកជិតស្លាប់ | (L*F) | 50 | 51.50 | 53.05 | 54.64 | 56.28 | 57.96 | 59.70 | 61.49 | 63.34 | 65.24 | 67.20 |
| | **ករណីគោលនយោបាយ (មានបញ្ញត្តិកម្ម)** | | | | | | | | | | | | | |
| P | - ចំនួនអាងហែលទឹកដែលមានរបង | | 100,000 | 115,000 | 130,450 | 146,364 | 162,754 | 179,637 | 197,026 | 214,937 | 233,385 | 252,387 | 271,958 |
| Q | - ចំនួនអាងហែលទឹកដែលមិនមានរបង | | 400,000 | 400,000 | 400,000 | 400,000 | 400,000 | 400,000 | 400,000 | 400,000 | 400,000 | 400,000 | 400,000 |
| R | *អាងហែលទឹកបន្ថែមមានរបង (ឆ្នាំនេះ)* | *(change in S)* | | 12,000 | 12,360 | 12,731 | 13,113 | 13,506 | 13,911 | 14,329 | 14,758 | 15,201 | 15,657 |
| S | អាងហែលទឹកបន្ថែមមានរបង (ឆ្នាំ២០១៧) | *(P-L)* | | 12,000 | 24,360 | 37,091 | 50,204 | 63,710 | 77,621 | 91,950 | 106,708 | 121,909 | 137,567 |
| T | ចំនួនក្មេងលង់ទឹកស្លាប់ | (R*E) | 20 | 20 | 20 | 20 | 20 | 20 | 20 | 20 | 20 | 20 | 20 |
| U | ចំនួនក្មេងលង់ទឹកជិតស្លាប់ | (R*F) | 50 | 50 | 50 | 50 | 50 | 50 | 50 | 50 | 50 | 50 | 50 |
| V | *ការកាត់បន្ថយការលង់ទឹកស្លាប់* | *(T-N)* | | - 0.60 | - 1.22 | - 1.85 | - 2.51 | - 3.19 | - 3.88 | - 4.60 | - 5.34 | - 6.10 | - 6.88 |
| W | *ការកាត់បន្ថយការលង់ទឹកជិតស្លាប់* | *(U-O)* | | - 1.50 | - 3.05 | - 4.64 | - 6.28 | - 7.96 | - 9.70 | - 11.49 | - 13.34 | - 15.24 | - 17.20 |
| | បន្ទុកចំណាយ | | | | | | | | | | | | | |
| | ថ្លៃតម្លើងរបងបន្ថែម | (R*A) | | -$30,000,000 | -$30,900,000 | -$31,827,000 | -$32,781,810 | -$33,765,264 | -$34,778,222 | -$35,821,569 | -$36,896,216 | -$38,003,102 | -$39,143,196 |
| | ថ្លៃថែទាំរបងបន្ថែម | (S*B) | | -$300,000 | -$609,000 | -$927,270 | -$1,255,088 | -$1,592,741 | -$1,940,523 | -$2,298,739 | -$2,667,701 | -$3,047,732 | -$3,439,164 |
| | ថ្លៃចុះអធិការកិច្ចរបស់រដ្ឋាភិបាល | (C*D*S) | | -$150,000 | -$304,500 | -$463,635 | -$627,544 | -$796,370 | -$970,261 | -$1,149,369 | -$1,333,850 | -$1,523,866 | -$1,719,582 |
| | ឆន្ទៈក្នុងការចំណាយដើម្បីកាត់បន្ថយការ | (V*G) | | $1,800,000 | $3,654,000 | $5,563,620 | $7,530,529 | $9,556,444 | $11,643,138 | $13,792,432 | $16,006,205 | $18,286,391 | $20,634,983 |
| | ឆន្ទៈក្នុងការចំណាយដើម្បីកាត់បន្ថយការរបួស | (W*G*K) | | $900,000 | $1,827,000 | $2,781,810 | $3,765,264 | $4,778,222 | $5,821,569 | $6,896,216 | $8,003,102 | $9,143,196 | $10,317,491 |
| | ជៀសវាការចំណាយថ្លៃសុខភាពរយៈពេលខ្លី និងរយៈពេលវែង | (W*H) + (W*I) | | $757,500 | $1,537,725 | $2,341,357 | $3,169,097 | $4,021,670 | $4,899,820 | $5,804,315 | $6,735,945 | $7,695,523 | $8,683,889 |
| | ផលប៉ះពាល់សុទ្ធ | | | -$26,992,500 | -$24,794,775 | -$22,531,118 | -$20,199,552 | -$17,798,038 | -$15,324,480 | -$12,776,714 | -$10,152,515 | -$7,449,591 | -$4,665,578 |
| | **សរុប (មិនបញ្ចុះតម្លៃ)** | | -$162,684,861 | | | | | | | | | | |
| | **តម្លៃបច្ចុប្បន្នសុទ្ធ (NPV)** | | -$123,876,080 | | | | | | | | | | |

# ហិរញ្ញប្បទានដោយ
# ធនាគារអភិវឌ្ឍន៍អាស៊ី

ADB